ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១៣០ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ៣ ឆ្នាំ២០១៦

# ប្រកាស

## ស្តីពី

## លក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រគេនរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតរង្វាន់ពិសេសសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- យោងតាមតម្រូវការចាំបាច់ការងារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់អំពីលក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការប្រឡងប្រណាំង "**ពានរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី** និង**ប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍**"។

**ប្រការ ២.-**

ប្រកាសនេះមានគោលបំណង ដូចតទៅ៖

- ធានាបាននូវការចូលរួម និងការវាយតម្លៃប្រកបដោយតម្លាភាព សុក្រឹតភាព និងប្រសិទ្ធភាពក្នុងចលនាប្រឡងប្រណាំង "**ពានរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី** និង**ប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍**"។
- ផ្តល់ការលើកទឹកចិត្តដល់សហគ្រាស ឬប្រតិបត្តិករ ឬសហគមន៍ ឬបុគ្គលដែលមានស្នាដៃឆ្នើមក្នុងការលើកស្ទួយ និងអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសក្នុងការទ្រទ្រង់ចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**"។

## ជំពូកទី២

## អំពីប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍

**ប្រការ ៣.-**

ប្រភេទនៃរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ត្រូវបានកំណត់ដូចខាងក្រោម៖

- រង្វាន់សម្រាប់ "**ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការថែរក្សាអនាម័យ និងបរិស្ថាន**"
- រង្វាន់សម្រាប់ "**ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ ៣ R**"
- រង្វាន់សម្រាប់ "**ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌**"
- រង្វាន់សម្រាប់ "**ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ**"
- រង្វាន់សម្រាប់ "**សហគ្រិនដែលមានស្នាដៃឆ្នើម**"
- រង្វាន់សម្រាប់ "**ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការថែរក្សាឆ្នេរសមុទ្រ**"
- រង្វាន់សម្រាប់ "**ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ**"

ប្រភេទនៃរង្វាន់នីមួយៗសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍មានសុពលភាពរយៈពេល០២(ពីរ)ឆ្នាំ។ ប្រភេទនៃរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍អាចត្រូវបានកែសម្រួលក្នុងករណីចាំបាច់ តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ ៤.-**

ប្រភេទនៃរង្វាន់សម្រាប់ធុរកិច្ចបៃតងនីមួយៗនឹងត្រូវផ្តល់ជូនសហគ្រាស ឬប្រតិបត្តិករ ឬសហគមន៍ ឬបុគ្គលទាំងឡាយណាដែលបានបំពេញតាមលក្ខខណ្ឌតម្រូវដូចដែលមានកំណត់ក្នុង**ស្តង់ដាររង្វាន់ធុរកិច្ចបៃតង** ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៥.-**

ប្រភេទនៃរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ត្រូវបានផ្តល់ជូនក្រោមទម្រង់ជាវិញ្ញាបនបត្រទទួលស្គាល់ និងអេកូឡាបិល។

គំរូនៃប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងគំរូវិញ្ញាបនបត្រទទួលស្គាល់ អេកូឡាបិល ត្រូវកំណត់ក្នុងស្តង់ដាធុរកិច្ចបៃតងដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៣
## អំពីលក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការប្រឡងប្រណាំង

**ប្រការ ៦.-**

លក្ខណវិនិច្ឆ័យនៃប្រភេទរង្វាន់នីមួយៗសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ត្រូវបានកំណត់ក្នុងស្តង់ដារង្វាន់ធុរកិច្ចបៃតងដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៧.-**

ក្រសួងទេសចរណ៍ ត្រូវបង្កើតគណៈកម្មការរៀបចំ និងវាយតម្លៃរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។

គណៈកម្មការរៀបចំ និងវាយតម្លៃរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ត្រូវដឹកនាំដោយអគ្គនាយកជំនាញ និងមានលេខាធិការដ្ឋានមួយជាជំនួយការ។

ស្ថាប័នជំនាញឯករាជ្យមួយត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ ដើម្បីសម្របសម្រួលដំណើរការប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។

**ប្រការ ៨.-**

ក្រសួងទេសចរណ៍ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនៃចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។

អ្នកស្នើសុំរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ត្រូវដាក់ពាក្យមកក្រសួងទេសចរណ៍ដោយគោរពតាមកាលបរិច្ឆេទ និងលក្ខខណ្ឌនានាដែលកំណត់ដោយក្រសួង។

**ប្រការ ៩.-**

អ្នកស្នើសុំអាចស្វែងរកស្ថាប័នជំនាញឯករាជ្យ ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ក្នុងការប្រឹក្សាយោបល់ និងបច្ចេកទេសលើការបំពេញពាក្យសុំ ការរៀបចំឯកសារតម្រូវពាក់ព័ន្ធនានាដើម្បីអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការស្នើសុំរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។

**ប្រការ ១០.-**

ក្រោយពីទទួលបានពាក្យស្នើសុំត្រឹមត្រូវ គណៈកម្មការរៀបចំ និងវាយតម្លៃរង្វាន់សម្ដេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ មានរយៈពេលហុកសិប (៦០) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីធ្វើការត្រួតពិនិត្យ និងជូនដំណឹងអំពីការវាយតម្លៃបឋមរបស់ខ្លួនដល់អ្នកស្នើសុំ។

ក្រោយការត្រួតពិនិត្យបឋមលើពាក្យស្នើសុំ គណៈកម្មការរៀបចំ និងវាយតម្លៃរង្វាន់សម្ដេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ មានរយៈពេលសាមសិប (៣០) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីចាត់តាំងក្រុមការងារចុះត្រួតពិនិត្យលើទីតាំងផ្ទាល់ និងប្រមូលទិន្នន័យពាក់ព័ន្ធនានាដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃសម្រេចចុងក្រោយ។

ក្រសួងទេសចរណ៍ ត្រូវចេញរបាយការណ៍វាយតម្លៃចុងក្រោយ និងធ្វើការប្រកាសជ័យលាភីរង្វាន់សម្ដេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់ការវាយតម្លៃលើទីតាំងផ្ទាល់។

**ប្រការ ១១.-**

ការវាយតម្លៃរង្វាន់សម្ដេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ អាចធ្វើលើសពីមួយដងតាមសំណូមពរចាំបាច់របស់អ្នកស្នើសុំ។

**ប្រការ ១២.-**

ករណីអ្នកស្នើសុំពុំអាចបំពេញបានតាមលក្ខណវិនិច្ឆ័យដូចបានកំណត់ក្នុងស្តង់ដាររង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ក្រសួងទេសចរណ៍ត្រូវជូនដំណឹងដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ដល់អ្នកស្នើសុំ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់ការវាយតម្លៃបឋម ឬការវាយតម្លៃលើទីតាំងផ្ទាល់។

## ជំពូកទី៤

## ទោសប្បញ្ញត្តិ

**ប្រការ ១៣.-**

ការប្រើប្រាស់ ឬផ្សព្វផ្សាយរង្វាន់សម្ដេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដែលហួសសុពលភាព ឬគ្មានការទទួលស្គាល់ពីក្រសួងទេសចរណ៍ ត្រូវចាត់ទុកថាខុសច្បាប់ និងត្រូវទទួលពិន័យស្របតាមមាត្រា ៧៣ នៃច្បាប់ស្តីពីទេសចរណ៍។

ការពិន័យខាងលើនេះ មិនធ្វើឱ្យសហគ្រាស ឬប្រតិបត្តិករ ឬសហគមន៍ ឬបុគ្គលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណីឡើយ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១៥.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ក្រុមអ្នកច្បាប់ ប្រធានគ្រប់នាយកដ្ឋាន និងប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

***កន្លែងទទួល:-***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ដូចប្រការ ១៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ឧបសម្ព័ន្ធនៃប្រកាស លេខ១៣០ ប្រក

# ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦

# ស្តីពីលក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការប្រឡងប្រណាំងថ្នាក់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រគេនថ្នាក់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍

# មាតិកា

I. **សេចក្តីផ្តើម** ........ ២

១.១ គោលបំណង ........ ២

១.២ អត្ថប្រយោជន៍ ........ ៣

១.៣ វិធីសាស្ត្រនៃការរៀបចំស្តង់ដា ........ ៤

II. **ស្តង់ដា** ........ ៥

២.១. វង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន" ........ ៦

២.២. វង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ ៣Rs" ........ ៩

២.៣. វង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌" ........ ១២

២.៤. វង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ" ........ ១៥

២.៥. វង្វាន់សម្រាប់ "សហគ្រិនដែលមានស្នាដៃឆ្នើម" ........ ១៨

២.៦. វង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាឆ្នេរសមុទ្រ" ........ ២០

២.៧. វង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ" ........ ២៤

III. **លក្ខខណ្ឌពិន្ទុ និងវិញ្ញាបនបត្រទទួលស្គាល់** ........ ២៥

IV. **យន្តការ និងនីតិវិធីសម្រាប់ដាក់ឲ្យដំណើរការវង្វាន់** ........ ៣២

៤.១. យន្តការនៃការដាក់ឲ្យដំណើរការ ........ ៣២

៤.២. នីតិវិធីនៃដំណើរការ ........ ៣២

## ស្តង់ដា
## "រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"
## (Eco-Business Awards for Tourism)

### I. សេចក្តីផ្តើម

បច្ចុប្បន្នពិភពលោកទាំងមូលបាននឹងកំពុងប្រឈមនឹងការវិវត្តថ្មីៗឥតឈប់ឈរទាំងលើមូលដ្ឋានសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ដែលស្តែងឡើងតាមរយៈការប្រែប្រួលជាច្រើនដូចជា **ភាពមិនប្រាកដប្រជានៃវិបត្តិសេដ្ឋកិច្ចសកលលោក បញ្ហាគ្រោះធម្មជាតិកើតឡើងជាបន្តបន្ទាប់មានជាអាទិ៍ ការកើនឡើងកំដៅផែនដី ការរលាយទឹកកកនៅតំបន់ប៉ូល រលកយក្ស (Tsunami) ទឹកជំនន់ និងខ្យល់ព្យុះ**ជាដើម។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ ការយកចិត្តទុកដាក់ដល់**ទស្សនទានបៃតង**គឺពិតជាមានភាពចាំបាច់ និងមានសារៈសំខាន់ជាមូលដ្ឋាន ខណៈពេលដែលពិភពលោកទាំងមូលកំពុងបោះជំហានទៅមុខនៅក្នុងសម័យកាល**បៃតង**។ ឈរលើទស្សនទាននេះ **ការអភិវឌ្ឍបៃតង**ដែលជាគំរូអភិវឌ្ឍន៍គិតគូរដល់ការអភិរក្ស ការថែរក្សាសម្បត្តិវប្បធម៌ ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព គឺពិតជាមានសារៈសំខាន់ និងចាំបាច់ស្របនឹងពេលវេលា និងតម្រូវការបច្ចុប្បន្នក្នុងការធានានិរន្តរភាព។ ក្នុងន័យនេះ ការអភិវឌ្ឍបៃតង គឺស្របនឹង **គំរូអភិវឌ្ឍបៃតង និងស្អាត** (Green and Clean Development Model) ដែលជាជំរើសដ៏វៃឆ្លាត និងសក្តិសមបំផុតនាពេលបច្ចុប្បន្នដោយត្រូវធានាឲ្យបាននូវ**និរន្តរភាព និងតុល្យភាពខាងផ្នែកសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌**។

ទាំងនេះទាមទារឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ហើយការចូលរួមនៅទីនេះគឺមិនត្រឹមតែផ្តោតលើផ្នែករដ្ឋដែលជាអ្នកដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែផ្នែកឯកជនក៏ត្រូវចូលរួមដល់ការធានានិរន្តរភាព តាមរយៈ**ការកែសម្រួលទម្រង់នៃការធ្វើធុរកិច្ច** (Business Pattern) ដោយត្រូវចាប់ផ្តើមយកចិត្តទុកដាក់ដល់ទស្សនទាននៃ **"ការទទួលខុសត្រូវរបស់សហគ្រាសលើផ្នែកសង្គម"** (Corporate Social Responsibility-CSR)។ ស្តង់ដា ***"រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"*** សំដៅជម្រុញលើកទឹកចិត្តដល់ធុរកិច្ចបៃតងនៅកម្ពុជាដែលពិតជាមានសារៈសំខាន់ និងចាំបាច់ជាមូលដ្ឋានសមស្របនឹងនិន្នាការបច្ចុប្បន្ន។

#### ១.១ គោលបំណង

**ធុរកិច្ចបៃតង**សំដៅលើការចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ តាមរយៈការធ្វើធុរកិច្ចដែលមានការយកចិត្តទុកដាក់ពីផលប៉ះពាល់បរិស្ថាន ការលើកកំពស់សុខុមាលភាពសង្គម ការថែរក្សា និងលើកស្ទួយវប្បធម៌ ជាដើម។

**សហគ្រាស** សំដៅលើស្ថាប័ន ឬអង្គភាព(បណ្តុំមនុស្ស និងទ្រព្យសកម្ម) ដែលធ្វើសកម្មភាពអាជីវកម្មនៅក្នុងវិស័យទេសចរណ៍ វិស័យសេវាកម្មទេសចរណ៍ផ្សេងៗ និងក្នុងវិស័យដទៃទៀតដែលគាំទ្រ និងបំរើដល់វិស័យទេសចរណ៍ ក្នុងគោលបំណងដើម្បីទទួលបាននូវប្រាក់ចំណេញ។ ជាទូទៅ ប្រភេទសហគ្រាស ឬបុគ្គលដែលអាចចូលរួមប្រឡងប្រណាំងមានដូចខាងក្រោម៖

1- សណ្ឋាគារ
2- ភោជនីយដ្ឋាន
3- រមណីយដ្ឋាន
4- សហគមន៍ទេសចរណ៍
5- សហគ្រាសធុនតូចនិងមធ្យម (SME) ផលិតវត្ថុអនុស្សាវរីយ៍
6- Shopping Center
7- សហគ្រិនវ័យក្មេង ឬ វិនិយោគិន
8- ធុរកិច្ចពាក់ព័ន្ធ និងគាំទ្រវិស័យទេសចរណ៍

ដូច្នេះ ការបង្កើតឲ្យមានស្តង់ដា ***"រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"*** គឺជាគំនិតផ្តួចផ្តើមក្នុងគោលបំណងលើកកម្ពស់ធុរកិច្ចបៃតង និងគុណភាពសេវាល្អក្នុងវិស័យទេសចរណ៍នៅកម្ពុជាឲ្យកាន់តែប្រសើរឡើង។ ក្នុងន័យនេះ **សេវាល្អ** ***សំដៅដល់សេវារបស់ធុរកិច្ចដែលមានការពេញចិត្តពីអតិថិជន/ភ្ញៀវ និងដែលមានការគិតគូរពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងចំរើនដល់ផលប្រយោជន៍រួម ជាពិសេសចូលរួមធានានិរន្តរភាពនៃការអភិវឌ្ឍនៅកម្ពុជា ដោយមិនគ្រាន់តែអាស្រ័យលើនិរន្តរភាពផ្នែកហិរញ្ញវត្ថុតែមួយមុខប៉ុណ្ណោះទេ តែក៏ត្រូវផ្តោតការយកចិត្តទុកដាក់លើនិរន្តរភាពផ្នែកបរិស្ថាន សង្គម និងវប្បធម៌ផងដែរ*** សំដៅគាំទ្រដល់ចលនាប្រឡងប្រណាំង **"រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** និងយុទ្ធនាការឃោសនាផ្សព្វផ្សាយទេសចរណ៍ **"កម្ពុជាៈ ព្រះរាជាណាចក្រអច្ឆរិយៈ"** ។

ស្តង់ដា***"រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"*** មានសូចនាករជាច្រើនដែលផ្អែកលើមូលដ្ឋានសំខាន់ៗចំនួន៤ៈ **សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌**។ តាមរយៈខ្លឹមសាររបស់សូចនាករ ការបង្កើតស្តង់ដានេះមានគោលបំណងចង់ឲ្យសហគ្រាសផ្តោតជាសំខាន់ទៅលើចក្ខុវិស័យ និងគោលនយោបាយដែលផ្សារភ្ជាប់ជាមួយការអនុវត្តទាំងឡាយណាឆ្លើយតបទៅនឹងៈ

- សកម្មភាពពាណិជ្ជកម្មដែលមានទំនួលខុសត្រូវខាងផ្នែកសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌
- សកម្មភាពចូលរួមលើកស្ទួយសុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋ
- សកម្មភាពដែលមានកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធក្នុងការធានាឲ្យបាននូវនិរន្តរភាពលើគ្រប់វិស័យ
- ការមិនគិតតែពីផលចំណេញផ្នែកសេដ្ឋកិច្ចតែមួយមុខដែលមិនអាចធានាឲ្យទទួលបាននូវការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព។
- ការបង្កើនទំនាក់ទំនង និងភាពជាដៃគូសហប្រតិបត្តិការណ៍រវាងវិស័យឯកជននិងវិស័យសាធារណៈ

## ១.២ អត្ថប្រយោជន៍

ឡាបិលស្តីពី ***"រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"*** គឺជា គំនិតផ្តួចផ្តើមថ្មីមួយសម្រាប់កម្ពុជា ខណៈដែលបណ្តាប្រទេសមួយចំនួនក្នុងតំបន់បាននិងកំពុងយកចិត្តទុក ដាក់ពីការចូលរួមរបស់សហគ្រាសក្នុងទំនួលខុសត្រូវផ្នែកសង្គម។ ស្របតាមបរិបទរបស់កម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ឡាបិលនេះគឺមានលក្ខណៈសាមញ្ញ និងអាចទទួលយកបានក្នុងការអនុវត្ត ពោលគឺមិនមានភាពតឹងរឹងដូចនៅបណ្តាលប្រទេសជឿនលឿនដទៃ

នោះទេ។ ការប្រើប្រាស់**គោលការណ៍ស្ម័គ្រចិត្ត** ជាយន្តការក្នុងការដាក់ឲ្យដំណើរការ ពោលសហគ្រាសអាចដាក់ពាក្យសុំចូលរួមដោយការស្ម័គ្រចិត្ត។ ទោះបីជាយ៉ាងនេះក្តី ការចូលរួមរបស់សហគ្រាសក្នុងវិស័យឯកជនពិតជាមានសារៈសំខាន់ដែលនឹងផ្តល់ជាអត្ថប្រយោជន៍ជាច្រើនដូចខាងក្រោម៖

**<u>ចំពោះសហគ្រាស ឬបុគ្គល៖</u>**

ទទួលបានវិញ្ញាបនបត្រទទួលស្គាល់ និងអេកូឡាបិលដែលជាការទទួលស្គាល់ជាផ្លូវការថាបុគ្គល ឬសហគ្រាសបានចូលរួមក្នុងសកម្មភាពទំនួលខុសត្រូវផ្នែកសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដែលអាចជួយលើកស្ទួយមុខមាត់ និងកេរ្តិ៍ឈ្មោះរបស់បុគ្គល ឬសហគ្រាស។ រង្វាន់នេះនឹងក្លាយជាយុទ្ធសាស្ត្រផ្សព្វផ្សាយទីផ្សារក្នុងការទាក់ទាញអតិថិជនផងដែរ។ ស្តង់ដានេះអាចជួយសហគ្រាសក្នុងការកាត់បន្ថយចំណាយប្រតិបត្តិការតាមរយៈការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។

**<u>ចំពោះចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" ៖</u>**

រង្វាន់នេះនឹងក្លាយជាយន្តការទ្រទ្រង់ និងចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** នៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការជំរុញ និងការលើកទឹកចិត្តឲ្យមានការអនុវត្តដោយផ្ទាល់ ឬដោយប្រយោលពីសំណាក់សហគ្រាស ឬបុគ្គលក្នុងវិស័យឯកជនស្របតាមទស្សនទាននៃ**ភាពស្អាត និងបៃតង**។

**<u>ចំពោះសង្គមជាតិ៖</u>**

ចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ប្រកបដោយនិរន្តរភាព និងមានការបែងចែកប្រកបដោយសមធម៌ ជាពិសេសជួយលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅ របស់ប្រជាពលរដ្ឋដែលរួមចំណែកក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។

ឡាបិលនេះ ជាគំនិតផ្តួចផ្តើមថ្មីមួយទៀតនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ តាមរយៈការផ្តល់អាទិភាព និងការគិតគូរខ្ពស់ទៅលើធនធានធម្មជាតិ ធនធានថាមពល ការលើកស្ទួយ និងការអភិរក្សបេតិកភណ្ឌវប្បធម៌ និងកិច្ចការពារបរិស្ថាន ក្នុងគោលដៅរួមចំណែកដល់ការទប់ទល់បញ្ហាបំរែបំរួលអាកាសធាតុ និងរួមចំណែកដល់ការអភិវឌ្ឍ **"សេដ្ឋកិច្ចបៃតង"** នៅកម្ពុជា។

## ១.៣ វិធីសាស្ត្រនៃការរៀបចំស្តង់ដា

យោងទៅតាមគំរូ និងគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងគំរូអនុវត្តផងទៃទៀតដែលជាបទពិសោធន៍របស់បណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ ក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតសហការជាមួយអង្គការ Acting for life នៃសាធារណរដ្ឋបារាំង និងអ្នកពិគ្រោះយោបល់ឯករាជ្យ រៀបចំចងក្រងជាបណ្តុំសូចនាករ និងលក្ខណវិនិច្ឆ័យនៃឯកសារស្តង់ដា **"រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"** នេះឡើង។

**ទី១.<u>ការរៀបចំចងក្រងឯកសារ</u>៖** ស្តង់ដានេះរៀបចំបែងចែករង្វាន់ជា **០៧**ប្រភេទ ហើយរង្វាន់នីមួយៗត្រូវបានកំណត់ដោយសូចនាករ និងលក្ខណវិនិច្ឆ័យទាំងឡាយណា ដែលមានភាពបត់បែនទៅតាមភាពជាក់ស្តែងដោយមិនធ្វើឲ្យមានការប៉ះពាល់ដល់ប្រយោជន៍ពាណិជ្ជកម្មរបស់សហគ្រាសឡើយ។

**ទី២.** **<u>ការដាក់សាកល្បង៖</u>** នៅប្រទេសកម្ពុជា សហគ្រាសមួយចំនួនធ្លាប់មានបទពិសោធន៍ខាងផ្នែកធុរកិច្ចបៃតងរួចទៅហើយ ដែលភាគច្រើនជាប្រភេទសហគ្រាសបរទេសធំៗ ដែលមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជា។ រីឯសហគ្រាសតូចៗក្នុងស្រុកភាគច្រើនមិនធ្លាប់មានបទពិសោធន៍ខាងផ្នែកធុរកិច្ចបៃតងនេះទេ។ ដូច្នេះវាមានភាពចាំបាច់ណាស់ដែលលក្ខណវិនិច្ឆ័យនៃស្តង់ដានេះ តម្រូវឲ្យដាក់តេស្តសាកល្បងនៅតាមបណ្តាសហគ្រាសទាំងក្នុងវិស័យធនាគារ សេវាកម្ម ឧស្សាហកម្ម សមាគមក្នុងវិជ្ជាជីវៈទេសចរណ៍ និងអង្គការជាតិ និងអន្តរជាតិមួយចំនួនដែលមិនធ្លាប់មាន និងធ្លាប់មានបទពិសោធន៍អនុវត្តបៃតង ក្នុងគោលបំណងស្វែងយល់ពីស្ថានភាពជាក់ស្តែងនៅកម្ពុជា។

តាមរយៈកិច្ចសម្ភាសន៍ទាំងនោះ យើងក៏ទទួលបាននូវបទពិសោធន៍ និងព័ត៌មានសំខាន់ៗមួយចំនួនដែលជាជំនួយក្នុងការពិចារណាឡើងវិញក្នុងការរៀបចំលក្ខណវិនិច្ឆ័យនីមួយៗនៅក្នុងស្តង់ដាឲ្យមានភាពត្រឹមត្រូវ ភាពច្បាស់លាស់ ភាពអាចបត់បែនបាន និងអាចទទួលយកបានក្នុងបរិបទនៃប្រទេសកម្ពុជា។

## II. ស្តង់ដា

ស្តង់ដានេះមាន **០៧ ប្រភេទ** ដែលសហគ្រាស ឬបុគ្គលអាចដាក់ពាក្យសុំចូលរួមដោយស្ម័គ្រចិត្តសម្រាប់ប្រភេទរង្វាន់ណាមួយ ឬច្រើនប្រភេទរង្វាន់ក៏បានដោយមានការបញ្ជាក់ថាតើក្រុមហ៊ុននឹងសម្រេចរើសយករង្វាន់មួយណាឲ្យបានច្បាស់ក្នុងពេលបំពេញពាក្យសុំ។ ប្រភេទនៃរង្វាន់ទាំង **០៧** នោះរួមមាន៖

- ទី១. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន” (Environment Award)
- ទី២. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍៣Rs” (3Rs Award)
- ទី៣. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌” (Social Welfare and Cultural Heritage Award)
- ទី៤. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ” (Best Workplace Award)
- ទី៥. រង្វាន់សម្រាប់ “សហគ្រិនដែលមានស្នាដៃឆ្នើម” (Entrepreneur Award)
- ទី៦. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាឆ្នេរសមុទ្រ” (Beach Eco-Label Award)
- ទី៧. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ” (Khmer Product Usage Award)

### ២.១. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន”

រង្វាន់សម្រាប់ **“ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន”** មាន០៤សូចនាករ ដែលនឹងត្រូវផ្តល់ពិន្ទុតាមរយៈលក្ខណវិនិច្ឆ័យចំនួន **០៧** ដូចមានក្នុងតារាងខាងក្រោម៖

| រង្វាន់ | លក្ខណវិនិច្ឆ័យ | ការតាមដាន | ពិន្ទុ |
|---|---|---|---|
| **ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន** (Environment Award) | ការដាក់បញ្ចូលគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងសកម្មភាពអាជីវកម្ម ស្តែងឲ្យឃើញពីការចូលរួមរបស់ក្រុមហ៊ុនដល់ការថែរក្សា ការអភិរក្ស ការធ្វើឲ្យប្រសើឡើងនៃបរិស្ថាន និងការធានាថាផលប៉ះពាល់ដល់បរិស្ថាននឹងត្រូវកាត់បន្ថយឲ្យនៅត្រឹមកំរិតអប្បបរមា។ | | |
| | - ***ការគ្រប់គ្រងធនធានធម្មជាតិ និងថាមពលប្រកបដោយនិរន្តរភាព*** | | |
| | 1- មានការត្រួតពិនិត្យ និងតាមដានការប្រើប្រាស់ធនធានធម្មជាតិ និងថាមពល | មាន-មិនមាន | ២០% |
| | 2- មានការប្រើប្រាស់សំភារៈបរិក្ខាដែលជួយសន្សំសំចៃថាមពល ឬឧបករណ៍ដែលប្រើប្រាស់ថាមពលកកើតឡើងវិញ | មាន-មិនមាន | ២០% |
| | - ***ការគិតគូរពីតំបន់បៃតង*** | | |
| | 3- ការចូលរួមក្នុងសកម្មភាពដាំដើមឈើ | មាន-មិនមាន | ១០% |
| | 4- ការគិតគូរឲ្យមានតំបន់បៃតងនៅកន្លែងធ្វើការ | មាន-មិនមាន | ១០% |
| | - ***ការគិតគូរពីអនាម័យ*** | | |
| | 5- ការគិតគូរពីបញ្ហាអនាម័យក្នុងទីតាំងសហគ្រាស | មាន-មិនមាន | ១០% |
| | - ***ការគិតគូរពីការបំពុលបរិស្ថាន*** | | |
| | 6- ការគ្រប់គ្រងកាកសំណល់ជាតិពុលដែលបញ្ចេញទៅក្នុងបរិយាកាស ស្ទឹង ទន្លេ សមុទ្រ... | មាន-មិនមាន | ២០% |
| | 7- ការប្រើប្រាស់ផលិតផលដែលគិតគូរដល់បរិស្ថាន (Green product) | មាន-មិនមាន | ១០% |

### សេចក្តីអត្ថាធិប្បាយពីសូចនាករ និងលក្ខណវិនិច្ឆ័យ

រង្វាន់សម្រាប់ **“ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន”** មានគោលបំណងជំរុញឲ្យសហគ្រាសទាំងឡាយចូលរួមដល់ការថែរក្សាបរិស្ថាន និងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន។ រង្វាន់ប្រភេទនេះមានសូចនាករចំនួន ០៤ ដែលមានលក្ខណៈដូចខាងក្រោម៖

**ក. សូចនាករទី១.** ***ការគ្រប់គ្រងធនធានធម្មជាតិ និងថាមពលប្រកបដោយនិរន្តរភាព***

ដើម្បីធានានិរន្តរភាពផ្នែកបរិស្ថាន ការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ និងថាមពលពិតជាមានសារៈសំខាន់ណាស់ ព្រោះថាធនធានធម្មជាតិ និងថាមពលជាធនធានកម្រនៅលើផែនដីយើងនេះ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ និងប្រើប្រាស់ដោយប្រុងប្រយ័ត្នខ្ពស់។ ដូច្នេះ យើងបានកំនត់យកលក្ខណវិនិច្ឆ័យចំនួន **០២**ដែលសហគ្រាសគួរអនុវត្តតាម៖

➢ **លក្ខណៈវិនិច្ឆ័យទី១. ការត្រួតពិនិត្យ និងតាមដានការប្រើប្រាស់ធនធានធម្មជាតិ និងថាមពល**

ជាការពិតណាស់ ការយកចិត្តទុកដាក់របស់សហគ្រាសក្នុងការតាមដាន និងត្រួតពិនិត្យលើការប្រើប្រាស់ធនធានធម្មជាតិ និងថាមពល ជាពិសេសទឹក និងភ្លើងអគ្គិសនី តាមរយៈការកំនត់ជាគោលនយោបាយច្បាស់លាស់ក្នុងសហគ្រាស ការអប់រំ និងការបញ្ជ្រាបការយល់ដឹងដល់បុគ្គលិកឲ្យចេះសន្សំសំចៃជាដើម នេះជាការស្តែងឲ្យឃើញពីទំនួលខុសត្រូវរបស់សហគ្រាសក្នុងការប្រើប្រាស់ធនធាន ហើយវាក៏ចូលរួមដល់ការកាត់បន្ថយចំណាយរបស់សហគ្រាសបានមួយកម្រិតផងដែរ។

➢ **លក្ខណៈវិនិច្ឆ័យទី២. ការប្រើប្រាស់សំភារៈបរិក្ខាដែលជួយសន្សំសំចៃថាមពល ឬឧបករណ៍ដែលប្រើប្រាស់ថាមពលកកើតឡើងវិញ**

ទន្ទឹមនឹងនេះ មានវិធីសាស្ត្រមួយទៀតដែលមានប្រសិទ្ធភាពខ្ពស់ ហើយដែលប្រទេសជាច្រើននៅលើពិភពលោកបាននឹងកំពុងអនុវត្ត គឺការប្រើប្រាស់សំភារៈបរិក្ខាដែលជួយសន្សំសំចៃថាមពល ដូចជាអំពូលស៊ីភ្លើងតិច ឬការប្រើប្រាស់ឧបករណ៍ដែលដើរដោយថាមពលកកើតឡើងវិញ មានដូចជាថាមពលពន្លឺព្រះអាទិត្យ ការរចនាអគារដែលមានទម្រង់គិតគូរដល់បរិស្ថាន (Eco Building) ជាដើម។

**ខ. សូចនាករទី២.** ***ការគិតគូរពីតំបន់បៃតង***

តំបន់បៃតងសំដៅដល់ទីកន្លែងពោរពេញដោយសមាសធាតុបៃតង មានដូចជាដើមឈើ ស្មៅ ផ្កា និងរុក្ខជាតិជាដើម។ ដូច្នេះ យើងបានកំនត់យកលក្ខណៈវិនិច្ឆ័យចំនួន ០២ដែលសហគ្រាសគួរអនុវត្តតាម៖

➢ **លក្ខណៈវិនិច្ឆ័យទី៣. ការចូលរួមក្នុងសកម្មភាពដាំដើមឈើ**

សហគ្រាសត្រូវមានសកម្មភាពមួយចំនួន ដែលចូលរួមដល់ចលនានៃការដាំដើមឈើឡើងវិញក្រោមទម្រង់ជាការចូលរួមដោយផ្ទាល់ពីសំណាក់បុគ្គលិករបស់សហគ្រាស ឬក៏ជាជំនួយវិភាគទានដែលគាំទ្រដល់ចលនានេះ។

➢ **លក្ខណៈវិនិច្ឆ័យទី៤. ការគិតគូរឲ្យមានតំបន់បៃតងនៅកន្លែងធ្វើការ**

នៅកន្លែងធ្វើការមួយ ប្រសិនបើមានការគិតគូរឲ្យមានភាពបៃតងមិនត្រឹមតែជួយដល់ភាពស្រស់ស្អាតនៅកន្លែងនោះប៉ុណ្ណោះទេ តែថែមទាំងធ្វើឲ្យប្រសិទ្ធភាពការងាររបស់បុគ្គលិកមានការកើនឡើងទៀតផង ព្រោះតំបន់បៃតងនេះជាធាតុមួយចាំបាច់សម្រាប់មនុស្ស សត្វក្នុងការរក្សាលក្ខខណ្ឌជីវិតរស់នៅកាន់តែល្អប្រសើរ។ សហគ្រាសគួររៀបចំឲ្យមានជាតំបន់បៃតងនៅកន្លែងធ្វើការប្រមាណ ១០% - ២០% នៃផ្ទៃក្រឡាសរុបរបស់សហគ្រាស *(ដូចមានចែងក្នុងសូចនាករគោលនៃតំបន់បៃតងនៃស្តង់ដាទីក្រុងស្អាត)*។

**គ. សូចនាករទី៣.** ***ការគិតគូរពីអនាម័យ***

បញ្ហាអនាម័យស្អាតនៅក្នុង និងជុំវិញទីតាំងសហគ្រាសក៏ជាកត្តាចម្បងមួយចូលរួមទៅដល់ការលើកកម្ពស់ផ្នែកបដិសណ្ឋារកិច្ចរបស់សហគ្រាសផ្ទាល់ចំពោះអតិថិជន ឬភ្ញៀវរបស់ខ្លួន ព្រមទាំងចូលរួមផងដែរដល់ការអភិវឌ្ឍធុរៈកិច្ចបៃតងក្នុងវិស័យទេសចរណ៍។ ដូច្នេះ យើងបានកំនត់យកលក្ខណៈវិនិច្ឆ័យចំនួន០១ ដែលសហគ្រាសគួរអនុវត្តតាម៖

➢ **លក្ខណៈវិនិច្ឆ័យទី៥. ការគិតគូរពីបញ្ហាអនាម័យក្នុងទីតាំងសហគ្រាស**

សហគ្រាសគួររៀបចំឲ្យមានការយកចិត្តទុកដាក់ ឲ្យបានជាប់ជាប្រចាំទៅលើបញ្ហាអនាម័យ ដោយផ្តោតជាពិសេស ទៅលើទីតាំងទទួលភ្ញៀវ និងបរិវេណដែលអតិថិជន/ភ្ញៀវអាចទៅដល់។

ឃ. សូចនាករទី៤ *ការគិតគូរពីការបំពុលបរិស្ថាន*

សកម្មភាពរបស់សហគ្រាសតែងមានផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលទៅលើបរិស្ថាន។ ទោះបីជាផលប៉ះពាល់ទាំងនេះឋិតក្នុងកម្រិតតិចក្តី ច្រើនក្តី សហគ្រាសគួរគប្បីបង្ហាញពីទំនួលខុសត្រូវរបស់ខ្លួនលើការបំពុលបរិស្ថាន។ ដូច្នេះ យើងបានកំនត់យកលក្ខណវិនិច្ឆ័យចំនួន ០២ ដែលសហគ្រាសគួរអនុវត្តតាមៈ

- **លក្ខណវិនិច្ឆ័យទី៦. ការគ្រប់គ្រងកាកសំណល់ជាតិពុលដែលបញ្ចេញទៅក្នុងបរិយាកាស ស្ទឹង ទន្លេ សមុទ្រ...**

ដោយមើលឃើញថាសកម្មភាពមួយចំនួនរបស់សហគ្រាស បានជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថាន ដូចជាការបញ្ចេញកាកសំណល់ដែលមានជាតិពុលទៅក្នុងប្រភពទឹក ឬក្នុងបរិយាកាសជាដើម សហគ្រាសគប្បីត្រូវគោរពតាមច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមានស្តីពីបរិស្ថាន និងការគ្រប់គ្រងសំណល់ *(ដូចមានចែងក្នុងសូចនាករគោលនៃការគ្រប់គ្រងសំណល់រឹង និងរាវនៃស្តង់ដាទីក្រុងស្អាត)*។

- **លក្ខណវិនិច្ឆ័យទី៧. ការប្រើប្រាស់ផលិតផលដែលគិតគូរដល់បរិស្ថាន**(Green product)

បច្ចុប្បន្ន ប្រជាជននៃបណ្តាប្រទេសភាគច្រើនកំពុងមាននិន្នាការចូលចិត្តប្រើប្រាស់ផលិតផលណាដែលជួយថែរក្សាបរិស្ថាន។ ផលិតផលទាំងនោះមានដូចជា ផលិតផលដែលផលិតពីវត្ថុធាតុដើមដែលត្រូវបានកែច្នៃពីសំណល់ ឬផលិតផលកែច្នៃ ផលិតផលដែលគ្មានសារធាតុបំពុលដល់បរិស្ថាន ផលិតផលដែលអាចប្រើប្រាស់ ឬអាចកែច្នៃឡើងវិញបានជាដើម។ ដូច្នេះសហគ្រាសត្រូវមានគោលនយោបាយក្នុងការប្រើប្រាស់ផលិតផលដែលគិតគូរដល់បរិស្ថានទាំងនេះក្នុងដំណើរការធុរកិច្ចរបស់ខ្លួន។

***ចំពោះរង្វាន់ប្រភេទនេះ គឺទាមទារឲ្យសហគ្រាសបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់តែម្តង ពោលគឺ ១០០% នៃពិន្ទុសរុបដើម្បីទទួលបានរង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាបរិស្ថាន" ។***

## ២.២. រង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ ៣Rs"

រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ ៣Rs"** មាន០២សូចនាករ ដែលនឹងត្រូវផ្តល់ពិន្ទុតាមរយៈលក្ខណវិនិច្ឆ័យចំនួន ០៥ ដូចមានក្នុងតារាងខាងក្រោម៖

| **រង្វាន់** | **លក្ខណវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| **ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ ៣Rs** (3Rs Award) | ការចូលរួមអនុវត្តគោលការណ៍ក.ប.ក.*(ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ Reduce Reuse Recycle 3Rs)* ដែលរួមចំណែកដល់គោលនយោបាយនៃការគ្រប់គ្រងសំណល់ ពិសេសសំណល់ជាថង់ប្លាស្ទីក | | |
| | ***- ការអនុវត្តតាមគោលការណ៍ ៣Rs*** | | |
| | 1- ការលើកទឹកចិត្ត និងអនុវត្តការកាត់បន្ថយការប្រើប្រាស់ទាំងឡាយណាដែលមិនចាំបាច់ | មាន-មិនមាន | ២0% |
| | 2- ការលើកទឹកចិត្ត និងអនុវត្តការប្រើប្រាស់ផលិតផល ណាដែលអាចប្រើប្រាស់ម្តងទៀត ឬច្រើនដងបាន | មាន-មិនមាន | ២0% |
| | 3- ការលើកទឹកចិត្តដល់ការកែច្នៃសំណល់ និងការប្រើប្រាស់ផលិតផលដែលគិតគូរដល់បរិស្ថាន (Green product) | មាន-មិនមាន | ២0% |
| | 4- ការអនុវត្តគម្រោងគំរូជាក់ស្តែងនៅក្នុងសហគ្រាស | មាន-មិនមាន | ២0% |
| | ***- ការបែងចែកសំណល់*** | | |
| | 5- មានការបែកចែកសំណល់ទៅតាមប្រភេទ | មានបំពាក់ធុងសំរាមដែលមានការបែងចែក (សំណល់សរីរាង្គ សំណល់កែច្នៃបាន និងសំណល់ផ្សេងៗ) | ២0% |

### សេចក្តីអត្ថាធិប្បាយពីសូចនាករ និងលក្ខណវិនិច្ឆ័យ

រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍៣Rs"** នេះមានគោលបំណងធ្វើយ៉ាងណាឲ្យសហគ្រាសទាំងឡាយមានការគិតគូរដល់ការកាត់បន្ថយសំណល់ឲ្យបានជាអតិបរមាតាមរយៈការអនុវត្តគោលការណ៍ក.ប.ក. ៣Rs **(ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ)** និងចេះអនុវត្តវិធីសាស្ត្រនៃការបែងចែកសំណល់ទៅតាមប្រភេទ។ សកម្មភាពទាំងអស់នេះនឹងចូលរួមដល់ការពង្រឹងការលើកកំពស់សោភ័ណភាព និងការថែរក្សាបរិស្ថាន។ រង្វាន់ប្រភេទនេះមានសូចនាករចំនួន ០២ និងលក្ខណវិនិច្ឆ័យចំនួន ០៥ ដែលមានលក្ខណៈដូចខាងក្រោម៖

**ក. សូចនាករទី១.** ***ការអនុវត្តតាមគោលការណ៍ ក.ប.ក. ៣Rs***

ទន្ទឹមពេលដែលសេដ្ឋកិច្ចជាតិមានកំណើនយ៉ាងគំហុកគួរជាទីមោទនៈ កម្រិតជីវភាពរបស់ប្រជាពលរដ្ឋមានការប្រែប្រួលប្រសើរឡើងជាលំដាប់ អត្រាកំណើនប្រជាសាស្ត្រប្រចាំឆ្នាំមានលំនឹងក្នុងរង្វង់ ២% ទៅ ៣%

គួបផ្សំនឹងការរីកលូតលាស់នៃតំបន់ទីប្រជុំជន បរិមាណសំណល់មានការកើនឡើងជាលំដាប់ ជាពិសេស សំណល់ប្លាស្ទិក ដែលជាបច្ច័យផ្ដើមចេញពីកំណើននៃការប្រើប្រាស់របស់មនុស្សដែលទាមទារឱ្យមានការយក ចិត្តទុកដាក់ខ្ពស់ក្នុងការកាត់បន្ថយ និងគ្រប់គ្រងឱ្យបានហ្មត់ចត់។ ដើម្បីចូលរួមដល់ការកាត់បន្ថយ និងគ្រប់គ្រង សំណល់ សហគ្រាសគួរគប្បីអនុវត្តតាមគោលការណ៍នៃ**ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ សំណល់ (ក.ប.ក. ៣Rs)** ដែលត្រូវបានទទួលស្គាល់ថាមានប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងសំណល់។ សហគ្រាសគួរមានគោលនយោបាយដែលឆ្លើយតបនឹងគោលការណ៍៣Rs ហើយត្រូវបង្ហាញថា គោលនយោបាយ នេះត្រូវបានយកទៅអនុវត្តជាក់ស្ដែង។ ដូច្នេះ លក្ខណវិនិច្ឆ័យចំនួន ០៤ ដែលសហគ្រាសគួរអនុវត្តតាមត្រូវបាន កំណត់ដូចខាងក្រោម៖

- **លក្ខណវិនិច្ឆ័យទី១. ការលើកទឹកចិត្ត និងអនុវត្តការកាត់បន្ថយការប្រើប្រាស់ទាំងឡាយណាដែលមិន ចាំបាច់**

ការកាត់បន្ថយសំដៅដល់ការកាត់បន្ថយការប្រើប្រាស់ទាំងឡាយណាដែលមិនចាំបាច់ ដែលបង្កើតជា សំណល់ ដោយជំនួសមកវិញនូវការសន្សំសំចៃ។ សហគ្រាសគួរមានជាគោលនយោបាយជំរុញលើកទឹកចិត្ត បុគ្គលិកឱ្យចេះកាត់បន្ថយការប្រើប្រាស់ដូចជា មិនគួរព្រីនឯកសារដែលមិនចាំបាច់ជំនួសដោយការមើលក្នុងកុំព្យូទ័រ ការកាត់បន្ថយការប្រើប្រាស់ក្រដាស់ ឬសំភារៈក្នុងការិយាល័យ ត្រូវប្រើប្រាស់ឱ្យអស់ពីលទ្ធភាពនូវ សំភារៈដែលអាចនៅប្រើបាន។ ចំពោះសំណល់ប្លាស្ទិក គួរកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកក្នុងករណីពុំចាំបាច់។

- **លក្ខណវិនិច្ឆ័យទី២. ការលើកទឹកចិត្តឱ្យចេះប្រើប្រាស់ផលិតផលណាដែលអាចប្រើប្រាស់ម្ដងទៀត ឬច្រើនដងបាន**

នៅក្នុងគោលនយោបាយនោះ គួរមានបញ្ចូលផងដែរនូវគោលការណ៍នៃការប្រើប្រាស់ឡើងវិញ។ ការ ប្រើប្រាស់ឡើងវិញ សំដៅដល់ការប្រើប្រាស់ផលិតផលណាដែលអាចប្រើប្រាស់ម្ដង ឬច្រើនដងទៀតបានដូចជា ការប្រើប្រាស់ក្រដាសថតចម្លងឯកសារទាំងសងខាង ការប្រើប្រាស់ថង់ប្លាស្ទិកដែលប្រើរួចឡើងវិញ និងការជួស ជុលសំភារៈ និងគ្រឿងអេឡិចត្រូនិចចាស់ៗដែលអាចប្រើប្រាស់ឡើងវិញដើម្បីសន្សំសំចៃថវិកាជាដើម។

- **លក្ខណវិនិច្ឆ័យទី៣. មានការលើកទឹកចិត្តដល់ការកែច្នៃសំណល់ និងការប្រើប្រាស់ផលិតផលដែល គិតគូរដល់បរិស្ថាន** (Green Product)

សហគ្រាសគួរធ្វើការលើកទឹកចិត្តដល់សកម្មភាពកែច្នៃសំណល់ តាមរយៈការចូលរួមគាំទ្រដល់កម្មវិធីកែ ច្នៃសំណល់របស់ស្ថាប័នដែលបាននឹងកំពុងមានសកម្មភាព ដូចជាកម្មវិធីដែលធ្វើឡើងដោយ យុវជននៅតាមសា សារៀន អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ឬស្ថាប័នពាក់ព័ន្ធនានា។ ជាមួយគ្នានេះដែរ សហគ្រាសគប្បីលើកទឹកចិត្ត ដល់ការញែកសំរាម ដោយទុកដាក់សំណល់ទៅតាមប្រភេទ (សំណល់សរីរាង្គ សំណល់កែច្នៃបាន និងសំណល់ ផ្សេងៗ) ដែលនឹងចូលរួមគាំទ្រដល់សកម្មភាពកែច្នៃសំណល់។ មិនតែប៉ុណ្ណោះ គួរមានការជំរុញលើកទឹកចិត្តដល់ បុគ្គលិកឱ្យគាំទ្រប្រើប្រាស់ផលិតផលដែលផលិតពីវត្ថុធាតុដើមដែលត្រូវ បានកែច្នៃពីសំណល់ ឬផលិតផលកែច្នៃ ផលិតផលដែលគ្មានសារធាតុបំពុលដល់បរិស្ថានផលិតផលដែល អាចប្រើប្រាស់ ឬអាចកែច្នៃឡើងវិញបានជាដើម ដើម្បីគាំទ្រដល់ចលនានៃការកាត់បន្ថយសំណល់ឆ្ពោះទៅរកនិរន្តរភាពផ្នែកបរិស្ថាននៅ កម្ពុជា។ ចំពោះសំណល់ប្លាស្ទិកដែលជាបញ្ហាប្រឈមចំបងនាពេលបច្ចុប្បន្ន សហគ្រាសគប្បីងាកមកប្រើប្រាស់

ផលិតផលជំនួស ដូចជាការប្រើប្រាស់**ថង់បរិស្ថាន** (Eco-bag) សំភារៈវេចខ្ចប់ផលិតពីវត្ថុធាតុដើមធម្មជាតិ (ដូចជា ឬស្សី ផ្តៅ ល្ពាក់ កំប្លោក...ជាដើម) ជំនួសឲ្យថង់ប្លាស្ទិក។

➢ **លក្ខណវិនិច្ឆ័យទី៤. ការអនុវត្តគម្រោងគំរូជាក់ស្តែងនៅក្នុងសហគ្រាស**

សហគ្រាសគួររៀបចំបង្កើតគម្រោងអនុវត្តគំរូ (Pilot Project) នៅក្នុងសហគ្រាស។ គម្រោងគំរូនេះអនុវត្តទៅលើគោលការណ៍ **៣Rs** ដើម្បីបង្ហាញថាសហគ្រាសមិនត្រឹមតែមានជាគោលនយោបាយប៉ុណ្ណោះទេ តែថែមទាំងមានការអនុវត្តជាក់ស្តែង និងធ្វើជាគំរូល្អនៅក្នុងសង្គមទៀតផង ដោយអប់រំបញ្ជ្រាបការយល់ដឹងដល់បុគ្គលិក បង្កើតកាលវិភាគជាក់ស្តែងក្នុងការអនុវត្តសកម្មភាព និងតាមដានលទ្ធផល។

**ខ. សូចនាករទី២.** ***ការបែងចែកសំណល់***

ការចូលរួមក្នុងការបែងចែកសំណល់ពិតជាមានសារសំខាន់ ដែលបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងសំណល់។ សូចនាករទី២នេះ មានលក្ខណវិនិច្ឆ័យចំនួន **០១**ដែលសហគ្រាសគួរអនុវត្តតាមៈ

➢ **លក្ខណវិនិច្ឆ័យទី៥. មានការបែកចែកសំណល់ទៅតាមប្រភេទ**

ការបែងចែកសំណល់ សំដៅដល់សកម្មភាពទាំងឡាយណាដែលចូលរួមដល់ការគ្រប់គ្រងសំណល់តាមរយៈការបែងចែកធុងសំរាមទៅតាមប្រភេទសំណល់ (**សំណល់កែច្នៃបាន សំណល់សរីរាង្គ និងសំណល់ផ្សេងៗ**) ដើម្បីជំរុញការទុកដាក់សំណល់ទៅតាមប្រភេទ។ សកម្មភាពនេះក៏មានសារៈសំខាន់ និងគាំទ្រដល់ការកែច្នៃសំណល់ផងដែរ។

***ចំពោះរង្វាន់ប្រភេទនេះ គឺទាមទារឲ្យសហគ្រាសបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់តែម្តង ពោល គឺ ១០០% នៃពិន្ទុសរុបដើម្បីទទួលបានរង្វាន់សម្រាប់ "ការអនុវត្តគោលការណ៍ ៣Rs" ។***

## ២.៣. រង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃផ្តើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌"

រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃផ្តើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌"** មាន០២សូចនាករ ដែលនឹងត្រូវផ្តល់ពិន្ទុតាមរយៈលក្ខណវិនិច្ឆ័យចំនួន **០៥** ដូចមានក្នុងតារាងខាងក្រោម៖

| **រង្វាន់** | **លក្ខណវិនិច្ឆ័យ** | **ការតាមដាន** | **ពិន្ទុ** |
|---|---|---|---|
| **ធុរកិច្ចដែលមានស្នាដៃផ្តើមផ្នែកសុខុមាលភាពសង្គម និង បេតិកភណ្ឌវប្បធម៌** (Social Welfare and Cultural Heritage Award) | ការយកចិត្តទុកដាក់របស់សហគ្រាសក្នុងការធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពសហគមន៍ និងសង្គម ព្រមទាំងចូលរួមដល់កិច្ចការថែរក្សា និងអភិរក្សទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌ គួរត្រូវបានលើទឹកចិត្ត និងទទួលស្គាល់តាមរយៈសកម្មភាពដូចខាងក្រោម៖ | | |
| | ***- ការចូលរួម និងគាំទ្រវាល់សកម្មភាពសប្បុរសធម៌ និងសកម្មភាពសង្គមនានា*** | | |
| | 1- ការផ្តល់ជំនួយដល់កុមារកំព្រាទុគ៌តជន ឬជនដែលងាយរងគ្រោះ | មាន-មិនមាន | ៣០% |
| | 2- ការផ្តល់សេវាកម្មសម្រាប់កិច្ចការអភិវឌ្ឍន៍សង្គម ឬសហគមន៍ | មាន-មិនមាន | ២០% |
| | ***- ការផ្តល់តម្លៃដល់ទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌*** | | |
| | 3- ចូលរួមដល់ការលើកស្ទួយទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌ | មាន-មិនមាន | ៣០% |
| | 4- ការផ្តល់តម្លៃដល់ការចេះដឹងពីទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌ | មាន-មិនមាន | ១០% |
| | 5- ការលើកតម្កើនផលិតផលក្នុងស្រុក ពិសេសផលិតដោយកសិករ និងសហគ្រាសខ្នាតតូច និងមធ្យម | មាន-មិនមាន | ១០% |

### សេចក្តីអត្ថាធិប្បាយពីសូចនាករ និងលក្ខណវិនិច្ឆ័យ

រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃផ្តើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌"** នេះមានគោលបំណងធ្វើយ៉ាងណាឲ្យសហគ្រាសទាំងឡាយមានការគិតគូរដល់បញ្ហាសង្គមជាសកល ដែលអាចពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយសកម្មភាពធុរកិច្ចរបស់សហគ្រាស។ និរន្តរភាពនៃការប្រកបធុរកិច្ចក៏ទាមទារផងដែរ នូវភាពសុខុដុមរមនាផ្នែកសង្គមវប្បធម៌ដែលជាកត្តាកំណត់ខាងក្រៅ (Exogenous Factors) មិនអាចខ្វះបានសម្រាប់ភាពជោគជ័យនៃអាជីវកម្មរបស់ខ្លួន។ រង្វាន់ប្រភេទនេះមានសូចនាករចំនួន **០២** និងលក្ខណវិនិច្ឆ័យចំនួន **០៤** ដែលមានលក្ខណៈដូចខាងក្រោម៖

**ក. សូចនាករទី១.** ***ការចូលរួម និងគាំទ្រវាល់សកម្មភាពសប្បុរសធម៌ និងសកម្មភាពសង្គមនានា***

សកម្មភាពសប្បុរសធម៌ និងការចេះជួយគ្នាក្នុងសង្គមគឺពិតជាមានភាពចាំបាច់ ដើម្បីធានាដល់ការអភិវឌ្ឍប្រកបដោយភាពសុខុដុមរមនា និងនិរន្តរភាព។ ទំនួលខុសត្រូវផ្នែកសង្គមរបស់សហគ្រាសត្រូវស្តែងឲ្យ

ឃើញតាមរយៈការចូលរួម និងគាំទ្ររាល់សកម្មភាពសប្បុរសធម៌ និងសកម្មភាពសង្គមនានា តាមរយៈការអនុវត្តតាមលក្ខណវិនិច្ឆ័យចំនួន ០២ ដូចខាងក្រោម៖

- **លក្ខណវិនិច្ឆ័យទី១. ការផ្តល់ជំនួយដល់កុមារកំព្រា ទុគ៌តជន ឬជនដែលងាយរងគ្រោះ**

សហគ្រាសត្រូវមានគោលនយោបាយ ក្នុងការផ្តល់ជាជំនួយវិភាគទានសំភារៈក្នុងមូលនិធិសប្បុរសធម៌នានាសម្រាប់ជួយដល់ជនប្រភេទទាំងនេះ កម្មវិធីផ្តល់អាហារូបករណ៍ចំនួនសិក្សាដល់សិស្ស-និស្សិតក្រីក្រដែលពុំមានលទ្ធភាពគ្រប់គ្រាន់បន្តការសិក្សានៅកំរិតឧត្តមសិក្សាបាន។ សកម្មភាពទាំងនេះអាចធ្វើឡើងក្រោមទម្រង់ជាកម្មវិធីដែលផ្តួចផ្តើមគំនិតដោយសហគ្រាសខ្លួនឯងផ្ទាល់ ឬក៏មានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនានា។

- **លក្ខណវិនិច្ឆ័យទី២. ការផ្តល់សេវាកម្មសម្រាប់កិច្ចការអភិវឌ្ឍន៍សង្គម ឬសហគមន៍**

សហគ្រាសគួរផ្តោតការយកចិត្តទុកដាក់ក្នុងការចូលរួមដល់កិច្ចការអភិវឌ្ឍន៍សង្គម ឬសហគមន៍ ដោយអាចផ្តល់ជាបុគ្គលិកស្ម័គ្រចិត្តឲ្យចុះជួយកិច្ចការមួយចំនួននៅតាមសហគមន៍ (ដូចជាសេវាកម្មបកប្រែ អ្នកសម្របសម្រួល រៀបចំវគ្គបណ្តុះបណ្តាល វគ្គបញ្ជ្រាបការយល់ដឹងដើម្បីជួយកសាងសមត្ថភាពរបស់សហគមន៍ជាដើម) ការចូលរួមដល់គំរោងអភិវឌ្ឍន៍មូលដ្ឋាននានានៅថ្នាក់សហគមន៍ និងសកម្មភាពសង្គមជាក់ស្តែងនានានៅថ្នាក់មូលដ្ឋាន-ល-។ ចំពោះសកម្មភាពទាំងនេះ សហគ្រាសអាចធ្វើដោយខ្លួនឯង ឬក្រោមកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនានា។

**ខ. សូចនាករទី២. *ការផ្តល់តម្លៃដល់ទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌***

ការថែរក្សា និងលើកស្ទួយទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌ដែលជាសម្បត្តិអរូបិយរបស់មនុស្សជាតិពិតជាមានសារៈសំខាន់ជាមូលដ្ឋាន និងមានតម្លៃពុំអាចកាត់ថ្លៃបានក្នុងការធានានិរន្តរភាពនៃការអភិវឌ្ឍបៃតងឈរលើមូលដ្ឋាននៃតុល្យភាពសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌។ ដើម្បីសម្រេចកិច្ចការនេះ សូចនាករទី១មានគោលបំណងចង់ឲ្យសហគ្រាសផ្តល់តម្លៃដល់ការថែរក្សាទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌ តាមរយៈការអនុវត្តតាមលក្ខណវិនិច្ឆ័យចំនួន ០៣ ដូចខាងក្រោម៖

- **លក្ខណវិនិច្ឆ័យទី៣. ការចូលរួមដល់ការលើកស្ទួយទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌**

សហគ្រាសត្រូវមានទំនួលខុសត្រូវចូលរួមដល់ការលើកស្ទួយទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌តាមរយៈការផ្តល់វិភាគទាន ឬជំនួយផ្នែកសំភារៈដល់ស្ថាប័នដែលធ្វើការពាក់ព័ន្ធនឹងកិច្ចការនេះ។ ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តនៅក្នុងគម្រោងចំណាយរបស់សហគ្រាសគួរមានកញ្ចប់ថវិកាជាក់លាក់ដោយឡែកមួយសម្រាប់សកម្មភាពនេះ។

- **លក្ខណវិនិច្ឆ័យទី៤ ការផ្តល់តម្លៃដល់ការចេះដឹងពីទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌**

សហគ្រាសត្រូវមានសកម្មភាពច្បាស់លាស់ក្នុងការផ្តល់តម្លៃដល់ការចេះដឹងពីទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌ ដូចជា ការអញ្ជើញក្រុមសិល្បៈបុរាណឲ្យមកសំដែងក្នុងកម្មវិធីផ្សេងៗនៅក្នុងសហគ្រាសមានការដាក់តាំង ឬប្រើប្រាស់នូវសំភារៈមួយចំនួនដែលបង្ហាញពីទំនៀមទំលាប់ប្រពៃណីវប្បធម៌នៅក្នុងសហគ្រាសរបស់ខ្លួន។

- **លក្ខណវិនិច្ឆ័យទី៥. ការលើកតម្កើនផលិតផលក្នុងស្រុក ពិសេសដែលផលិតដោយប្រជាកសិករ និងសហគ្រាសខ្នាតតូចនិងមធ្យម**

ការប្រើប្រាស់ផលិតផលក្នុងស្រុកគឺជាការជំរុញការនាំចេញនៅនឹងកន្លែង ដែលមានភាពចាំបាច់ធានាដល់និរន្តរភាព និងតុល្យភាពសេដ្ឋកិច្ចមូលដ្ឋាន ពិសេសផលិតផលដែលផលិតពីវត្ថុធាតុដើមធម្មជាតិដោយប្រជាកសិករ និងផលិតករក្នុងស្រុកជាការបង្ហាញពីអត្តសញ្ញាណជាតិដែលគួរត្រូវបានលើកតម្កើន។ ដូច្នេះ ការចូលរួមរបស់សហគ្រាសក្នុងការប្រើប្រាស់ និងការជំរុញលើកទឹកចិត្តបុគ្គលិកឲ្យប្រើប្រាស់ផលិតផលទាំងនោះពិតជាមានសារៈសំខាន់ណាស់ ដោយមិនត្រឹមតែចូលរួមក្នុងការថែរក្សាបរិស្ថាន និងការលើកកំពស់ជីវភាពតាមរយៈការបង្កើត និងបង្កើនឱកាសការងារ និងប្រាក់ចំណូលរបស់ប្រជាកសិករ និងផលិតករក្នុងស្រុកប៉ុណ្ណោះទេ តែក៏ជាការចូលរួមក្នុងការលើកស្ទួយវប្បធម៌របស់សង្គមជាតិផងដែរ។

*ចំពោះរង្វាន់ប្រភេទនេះ គឺទាមទារឲ្យសហគ្រាសបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់តែម្តង ពោលគឺ ១00% នៃពិន្ទុសរុបដើម្បីទទួលបានរង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃផ្តើមផ្តែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌" ។*

## ២.៤. រង្វាន់សម្រាប់ “ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ”

រង្វាន់សម្រាប់ **“ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ”** មាន០៣សូចនាករដែលនឹងត្រូវផ្តល់ពិន្ទុតាមរយៈលក្ខណវិនិច្ឆ័យចំនួន ០៦ ដូចមានក្នុងតារាងខាងក្រោម៖

| រង្វាន់ | លក្ខណវិនិច្ឆ័យ | ការតាមដាន | ពិន្ទុ |
|---|---|---|---|
| ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ (Best Workplace Award) | ការបង្ហាញពីលទ្ធភាពរបស់សហគ្រាសក្នុងការគ្រប់គ្រងទំនាក់ទំនងបុគ្គលិក និងការធានាឱ្យមានសុខុដុមរមនានៅកន្លែងធ្វើការត្រូវបានចាត់ទុកថាមានភាពចាំបាច់ និងជាកត្តាកំណត់ជោគជ័យអាជីវកម្ម គំនិតផ្តួចផ្តើមមួយចំនួនគួរត្រូវបានយកចិត្តទុកដាក់អនុវត្ត ដូចជា៖ | | |
| | *- លក្ខខណ្ឌទូទៅនៃការងារ* | | |
| | 1- អនុសញ្ញារួមនៃការងារ | មាន-មិនមាន | ២០% |
| | 2- ប្រាក់ខែសមរម្យដែលត្រូវធានា និងថិរវេលាធ្វើការ | ប្រាក់ខែសមរម្យ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ | ២០% |
| | *- បុគ្គលិក និងដំណើរការការងារ* | | |
| | 3- កម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិកទូទៅទាំងផ្នែកបដិសណ្ឋារកិច្ច និងផ្នែកជំនាញ | យ៉ាងហោចណាស់មានការបណ្តុះបណ្តាល១ដង ក្នុងមួយឆ្នាំ សម្រាប់បុគ្គលិកម្នាក់ | ១០% |
| | 4- ការរក្សាទំនាក់ទំនង និងដំណើរការការងារល្អនៅក្នុងសហគ្រាស | មាន-មិនមាន | ១០% |
| | *- ការគិតគូរពីសុខភាពនិងសុវត្ថិភាពរបស់បុគ្គលិក* | | |
| | 5- មានការធានារ៉ាប់រងសុខភាពដល់គ្រប់បុគ្គលិកទាំងអស់ | មាន-មិនមាន | ២០% |
| | 6- ការទទួលខុសត្រូវលើគ្រោះថ្នាក់ការងារ | មាន-មិនមាន | ២០% |

### សេចក្តីអត្ថាធិប្បាយពីសូចនាករ និងលក្ខណវិនិច្ឆ័យ

រង្វាន់សម្រាប់ **“ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ”** នេះមានគោលបំណងធ្វើយ៉ាងណាឱ្យសហគ្រាសទាំងឡាយមានការគិតគូរដល់សុខុមាលភាពរបស់បុគ្គលិក និងលក្ខខណ្ឌការងារកន្លែងធ្វើការ។ រង្វាន់ប្រភេទនេះមានសូចនាករចំនួន០៣ និងលក្ខណវិនិច្ឆ័យចំនួន០៦ ដែលមានលក្ខណៈដូចខាងក្រោម៖

**ក. សូចនាករទី១.** ***លក្ខខណ្ឌទូទៅនៃការងារ***

សហគ្រាសត្រូវមានគោលនយោបាយច្បាស់លាស់ដែលកំណត់ពីលក្ខខណ្ឌទូទៅនៃការងារ មុខរបរ តួនាទី និងភារកិច្ចរបស់កម្មករនិយោជិតឱ្យបានច្បាស់លាស់ និងគ្រប់គ្រងទំនាក់ទំនងល្អរវាងនិយោជក និងកម្មករ

និយោជិក សំដៅធ្វើឲ្យប្រសើរដល់បរិយាកាសការងារ ចូលរួមដល់កិច្ចធានាការពារកម្មករនិយោជិកទល់នឹងហានិភ័យសង្គម។ សូចនាករទី១នេះត្រូវបានកំនត់ដោយលក្ខណវិនិច្ឆ័យចំនួន ០២ ដូចខាងក្រោម៖

➢ **លក្ខណវិនិច្ឆ័យទី១. អនុសញ្ញារួមនៃការងារ**

សហគ្រាសត្រូវមានអនុសញ្ញារួមនៃការងារមានទម្រង់ជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងនិយោជកម្នាក់ ឬនិយោជកមួយក្រុម និងអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឲ្យកម្មករនិយោជិក (ដោយអនុលោមតាមជំពូកទី៥ នៃច្បាប់ស្តីពីការងារ)។

➢ **លក្ខណវិនិច្ឆ័យទី២. ស្តីពីប្រាក់ខែសមរម្យដែលត្រូវធានា និងថិរវេលាធ្វើការ**

សហគ្រាសត្រូវមានគោលការណ៍ និងប្រសិទ្ធភាពរបស់វាក្នុងការធានាឲ្យមានប្រាក់ខែសមរម្យសម្រាប់បុគ្គលិក (ជាប្រាក់ខែសមរម្យដែលអាចរ៉ាប់រងកម្មករនិយោជិកគ្រប់រូបឲ្យមានកំពស់ជីវភាពសមរម្យទៅតាមសេចក្តីថ្លៃថ្នូររបស់មនុស្ស) ដូចមានចែងក្នុងជំពូកទី៦ផ្នែកទី១ មាត្រា ១០៤ នៃច្បាប់ស្តីពីការងារ។ ចំពោះថេរវេលាធ្វើការនៃកម្មករនិយោជិតកទាំងពីរភេទមិនត្រូវឲ្យលើសពី០៨ម៉ោងក្នុងមួយថ្ងៃ ឬ**៤៨ម៉ោង**ក្នុងមួយអាទិត្យឡើយ ដូចមានចែងក្នុងជំពូកទី៦ផ្នែកទី២ មាត្រា **១៣៧** និង **១៣៩** ឬក៏មានភាពទូលំទូលាយជាងច្បាប់នេះក៏បាន។

**ខ. សូចនាករទី២. *បុគ្គលិក និងដំណើរការការងារ***

គ្រប់បុគ្គលិកទាំងអស់គួរទទួលបានការបណ្តុះបណ្តាលបន្ថែមដែលទាក់ទងនឹងតួនាទី និងភារកិច្ចរបស់ពួកគេ។ ភាពជោគជ័យរបស់សហគ្រាសគឺអាស្រ័យលើសមត្ថភាពការងាររបស់បុគ្គលិកគ្រប់ជាន់ថ្នាក់ គួបផ្សំនឹងបរិយាកាសទំនាក់ទំនង និងដំណើរការការងារមានភាពល្អប្រសើរ។ សូចនាករទី២នេះត្រូវបានកំនត់ដោយលក្ខណវិនិច្ឆ័យចំនួន ០២ ដូចខាងក្រោម៖

➢ **លក្ខណវិនិច្ឆ័យទី៣. កម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិកទូទៅ ទាំងផ្នែកបដិសណ្ឋារកិច្ច និងផ្នែកជំនាញ**

សហគ្រាសគួរមានកម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិកទូទៅទាំងផ្នែកបដិសណ្ឋារកិច្ច និងផ្នែកជំនាញ ហើយអាចធ្វើឡើងក្រោមទម្រង់ដូចជា ការបណ្តុះបណ្តាលនៅនឹងកន្លែង (In-house Training) ការបញ្ជូនបុគ្គលិកទៅសិក្សាវគ្គខ្លីៗ និងវគ្គវិក្រឹត្យការនានាក្នុងប្រទេស ឬក្រៅប្រទេស ឬអាចជាកម្មវិធីផ្តល់ឱកាសបំលាស់ទីបុគ្គលិកទៅកាន់សាខានៅក្រៅប្រទេសជាដើម។ ជាទូទៅបុគ្គលិកត្រូវទទួលបានការបណ្តុះបណ្តាលយ៉ាងហោចណាស់១ដងក្នុង១ឆ្នាំ។

➢ **លក្ខណវិនិច្ឆ័យទី៤. ការរក្សាទំនាក់ទំនង និងដំណើរការការងារល្អនៅក្នុងសហគ្រាស**

ការរក្សាទំនាក់ទំនង និងដំណើរការការងារល្អនៅក្នុងសហគ្រាសទាំងតាមរយៈខ្សែបណ្តោយ (Vertical Hierarchy) និងខ្សែទទឹង (Horizontal Hierarchy)គឺពិតជាមានសារៈសំខាន់ជាសារវ័ន្តសម្រាប់ធានាភាពរលូននិងភាពជោគជ័យក្នុងការប្រកបធុរកិច្ចរបស់សហគ្រាស។ ទំនាក់ទំនងផ្ទៃក្នុង (Internal Communication) និងកិច្ចសន្ទនា (Dialogue) រវាងនិយោជក និងនិយោជិក រវាងនិយោជិក និងនិយោជិកគ្រប់ជាន់ថ្នាក់គឺពិតជាមានសារៈសំខាន់ និងចាំបាច់ត្រូវមានវិធីសាស្ត្រច្បាស់លាស់។ សហគ្រាសគួរបង្កើតជាកម្មវិធីផ្សេងៗដែលជួយបង្កើនទំនាក់ទំនងល្អរវាងបុគ្គលិកនិងបុគ្គលិកគ្នាឯង ពិសេសរវាងអ្នកគ្រប់គ្រងជាមួយអ្នកក្រោមបង្គាប់ ព្រោះថាកត្តានេះពិតជាមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យប្រសិទ្ធភាពការងារមានការកើនឡើង។ កម្មវិធីទាំងនោះអាចជាការជប់លៀងប្រចាំឆ្នាំ ការធ្វើដំណើរកំសាន្តប្រចាំឆ្នាំ ទៅកាន់រមនីយដ្ឋានផ្សេងៗ ជាដើម។

**គ.សូចនាករទី៣.** ***ការគិតគូរពីសុខភាព និងសុវត្ថិភាពរបស់បុគ្គលិក***

និយោជិតដែលជាមូលធន (Human capital) ដែលមិនអាចខ្វះបានមានសិទ្ធិទទួលបានការធានារ៉ាប់រងផ្នែកសុខភាព និងសុវត្ថិភាពពេលបំពេញការងារឲ្យសហគ្រាស។ សហគ្រាសត្រូវមានការយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់បុគ្គលិក។ សូចនាករទី៣នេះ ត្រូវបានកំណត់ដោយលក្ខណវិនិច្ឆ័យចំនួន **០២** ដែលសហគ្រាសត្រូវបំពេញតាម៖

- **លក្ខណវិនិច្ឆ័យទី៥. ការធានារ៉ាប់រងសុខភាពដល់គ្រប់បុគ្គលិកទាំងអស់**

សហគ្រាសត្រូវមានធានារ៉ាប់រងផ្នែកសុខភាពដល់គ្រប់បុគ្គលិកទាំងអស់ ពោលគឺបុគ្គលិកត្រូវទទួលបានប្រាក់បន្ថែមសម្រាប់ថ្លៃពិនិត្យ និងព្យាបាលជំងឺប្រចាំឆមាស ឬប្រចាំឆ្នាំរបស់ពួកគេ។ ការកំនត់ទំហំទឹកប្រាក់សម្រាប់ចំណាយ ដែលជាបន្ទុករបស់សហគ្រាសត្រូវធានាថាមានភាពសមរម្យអាចទទួលយកបាន។

- **លក្ខណវិនិច្ឆ័យទី៦. ការទទួលខុសត្រូវលើគ្រោះថ្នាក់ការងារ**

សហគ្រាសក៏ត្រូវទទួលខុសត្រូវផងដែរចំពោះគ្រោះថ្នាក់ដែលអាចកើតមានពេលបុគ្គលិកកំពុងបំពេញការងារ ឬក្នុងពេលធ្វើដំណើរពីលំនៅស្ថានត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន (ដូចមានចែងក្នុងមាត្រា២៤៨ ជំពូកទី៩ នៃច្បាប់ស្តីពីការងារ) ពោលគឺកាត់បន្ថយគ្រោះថ្នាក់ការងារឲ្យនៅត្រឹមកំរិតអប្បបរមា។ មិនតែប៉ុណ្ណោះ សហគ្រាសក៏អាចធ្វើគោលនយោបាយរបស់ខ្លួនដែលមានភាពទូលំទូលាយជាងនេះក៏បាន។ (ឧទាហរណ៍៖ ការធានារ៉ាប់រងលើគ្រោះថ្នាក់ **២៤ ម៉ោង**សម្រាប់បុគ្គលិករបស់ខ្លួនជាដើម)។

*ចំពោះរង្វាន់ប្រភេទនេះ គឺទាមទារឲ្យសហគ្រាសបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់តែម្តង ពោលគឺ ១00% នៃពិន្ទុសរុបដើម្បីទទួលបានរង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃផ្តើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ"។*

**២.៥. រង្វាន់សម្រាប់ “សហគ្រិនដែលមានស្នាដៃឆ្នើម”**

រង្វាន់សម្រាប់ សហគ្រិនដែលមានស្នាដៃឆ្នើមត្រូវបានចែកជា **០២** ផ្នែករួមមាន៖

**១.** សហគ្រិនវ័យក្មេងឆ្នើម (សម្រាប់បេក្ខភាពទាំងពីរភេទដែលមានអាយុមិនលើសពី **៣៥ឆ្នាំ**)

**២.** វិនិយោគិនឆ្នើម (សម្រាប់បេក្ខភាពទាំងពីរភេទដែលមានអាយុលើសពី **៣៥ឆ្នាំ**)

រង្វាន់សម្រាប់ **“សហគ្រិនដែលមានស្នាដៃឆ្នើម”** មាន**០២**សូចនាករ ដែលនឹងត្រូវផ្តល់ពិន្ទុតាមរយៈលក្ខណវិនិច្ឆ័យចំនួន **០៤** ដូចមានក្នុងតារាងខាងក្រោម៖

| **រង្វាន់** | **លក្ខណវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| **សហគ្រិនដែលមានស្នាដៃឆ្នើម** (Entrepreneur Award) | សហគ្រិនដែលអាចនឹងទទួលបានជោគជ័យក្នុងអាជីវកម្មរបស់ខ្លួនគួរត្រូវបានទទួលស្គាល់ និងកោតសរសើរតាមរយៈសមត្ថភាព និងសកម្មភាព ដូចខាងក្រោម៖ | | |
| | - ***សមត្ថភាពរបស់សហគ្រិន*** | | |
| | 1- គំនិតផ្តួចផ្តើម និងការច្នៃប្រឌិតខ្ពស់ | មាន-មិនមាន | ៤0% |
| | 2- ភាពជោគជ័យផ្នែកហិរញ្ញវត្ថុ | មាន-មិនមាន | ២0% |
| | 3- ជំនាញ សមត្ថភាព និងភាពជាអ្នកដឹកនាំ | មាន-មិនមាន (វង្វាស់គុណភាព) | ៣0% |
| | -***ការផ្តល់ឱកាសក្នុងការកសាងសមត្ថភាពដល់អ្នកជំនាន់ក្រោយ*** | | |
| | 4- ការចែករំលែកបទពិសោធន៍ពីភាពជោគជ័យរបស់ខ្លួន | មាន-មិនមាន | ១0% |

## សេចក្តីអត្ថាធិប្បាយពីសូចនាករ និងលក្ខណវិនិច្ឆ័យ

វិស័យឯកជនបានដើរតួនាទីជាចលករយ៉ាងសំខាន់ក្នុងការចូលរួមដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច តាមរយៈការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ការបង្កើត និងបង្កើនឱកាសការងារជាដើម។ សហគ្រិនត្រូវចូលរួមដោយផ្ទាល់ក្នុងសកម្មភាពដឹកនាំសហគ្រាស ដោយមិនត្រឹមតែជាអ្នកចូលរួមផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ថែមទាំងជាអ្នកគ្រប់គ្រង ឬជានាយកប្រតិបត្តិផងដែរ។ រង្វាន់សំរាប់ **“សហគ្រិនដែលមានស្នាដៃឆ្នើម”** នឹងផ្តល់ជូនទៅដល់ *សហគ្រិនវ័យក្មេងអាចជាបុរស ឬស្ត្រី ដែលមាន**អាយុមិនលើសពី៣៥ឆ្នាំ** និងវិនិយោគិនអាចជាបុរស ឬស្ត្រី ដែលមាន**អាយុលើសពី៣៥ឆ្នាំ*** ក្នុងគោលបំណងលើកទឹកចិត្តដល់ពួកគាត់ដែលមានគំនិតផ្តួចផ្តើមចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចតាមរយៈការប្រកបអាជីវកម្ម និងធុរកិច្ចដោយខ្លួនឯង។ រង្វាន់ប្រភេទនេះមានសូចនាករចំនួន **០២** និងលក្ខណវិនិច្ឆ័យចំនួន **០៤**ដែលមានលក្ខណៈដូចខាងក្រោម៖

**ក. សូចនាករទី១.** ***សមត្ថភាពរបស់សហគ្រិន***

រាជរដ្ឋាភិបាលបច្ចុប្បន្នបាននឹងកំពុងជំរុញការគាំទ្រឲ្យមានគំនិតសហគ្រិនភាព និងភាពច្នៃប្រឌិតក្នុងវិស័យឯកជន។ នៅក្នុងសូចនាករទី១នេះត្រូវបានកំនត់ដោយលក្ខៈវិនិច្ឆ័យចំនួន **០៣** ដែលសហគ្រិនឆ្នើមត្រូវមានដូចខាងក្រោម៖

➢ **លក្ខណវិនិច្ឆ័យទី១. គំនិតផ្តួចផ្តើម និងការច្នៃប្រឌិតខ្ពស់**

សហគ្រាសផ្ញើមត្រូវតែជាអ្នកដែលមានគំនិតផ្តួចផ្តើមបង្កើតសហគ្រាសប្រកបដោយភាពច្នៃប្រឌិតខ្ពស់នៅក្នុងអាជីវកម្ម និងធុរកិច្ចរបស់ខ្លួន។ ពួកគេត្រូវតែជាអ្នកដឹកនាំដែលប្រកបដោយមនសិការការងារ និងចក្ខុវិស័យវែងឆ្ងាយ។

➢ **លក្ខណវិនិច្ឆ័យទី២. ភាពជោគជ័យផ្នែកហិរញ្ញវត្ថុ**

ជាមួយនឹងគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិតក្នុងការបង្កើតអាជីវកម្ម និងប្រកបធុរកិច្ចដោយខ្លួនឯង សហគ្រិនផ្ញើមវ័យក្មេង និងវិនិយោគិនត្រូវបង្ហាញពីស្នាដៃរបស់ខ្លួនតាមរយៈនិរន្តរភាព និងភាពជោគជ័យផ្នែកហិរញ្ញវត្ថុរបស់សហគ្រាស។

➢ **លក្ខណវិនិច្ឆ័យទី៣. ជំនាញ សមត្ថភាព និងភាពជាអ្នកដឹកនាំ**

ជំនាញ សមត្ថភាព និងភាពជាអ្នកដឹកនាំ ជាកត្តាសត្យានុម័តដែលកំនត់អំពីភាពជោគជ័យក្នុងការធ្វើធុរកិច្ចរបស់សហគ្រិន និងអ្នកដឹកនាំ។ ដូច្នេះ យើងកំនត់យកលក្ខណវិនិច្ឆ័យដែលទាក់ទងនឹងជំនាញ និងសមត្ថភាព (ទាំងកំរិតមូលដ្ឋាន កំរិតបច្ចេកទេស កំរិតគ្រប់គ្រង) និងភាពជាអ្នកដឹកនាំដែលសហគ្រិនវ័យក្មេង និងវិនិយោគិនត្រូវមានសមស្របទៅនឹងស្ថានភាព និងប្រភេទធុរកិច្ចដែលអនុវត្ត។

**ខ. សូចនាករទី២.** ***ការផ្តល់ឱកាសក្នុងការកសាងសមត្ថភាពដល់អ្នកជំនាន់ក្រោយ***

ការចែករំលែកចំណេះដឹង និងបទពិសោធន៍ត្នាទៅវិញទៅមកជាកត្តាចលករដ៏សំខាន់មួយចូលរួមដល់ការអភិវឌ្ឍថ្នាលធនធានមនុស្សប្រកបដោយគុណភាពសម្រាប់ប្រទេសជាតិទាំងមូល។ សូចនាករទី២នេះត្រូវបានកំនត់ដោយលក្ខណវិនិច្ឆ័យចំនួន ០១ ដែលសហគ្រិនផ្ញើមត្រូវមាន៖

➢ **លក្ខណវិនិច្ឆ័យទី៤. ការចែករំលែកបទពិសោធន៍ពីភាពជោគជ័យរបស់ខ្លួន**

សហគ្រិនផ្ញើមគួរចេះចែករំលែកចំណេះដឹង និងបទពិសោធន៍ពីភាពជោគជ័យរបស់ខ្លួនដល់អ្នក ជាពិសេសយុវជនជំនាន់ក្រោយៗទៀត សំដៅចូលរួមអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាឲ្យកាន់តែល្អប្រសើរឡើង។ ការចែករំលែកអាចធ្វើឡើងតាមរយៈការចូលរួមសិក្ខាសាលា ឬវេទិកាសាធារណៈដែលរៀបចំឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍របស់ជនដែលទទួលបានជោគជ័យក្នុងជីវិត ការសរសេរអត្ថបទអប់រំ និងការបង្ហាត់បង្ហាញដល់អ្នកនៅជុំវិញខ្លួនជាដើម។

***ចំពោះរង្វាន់ប្រភេទនេះ គឺទាមទារឲ្យសហគ្រិនវ័យក្មេង ឬវិនិយោគិនបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់តែម្តង ពោលគឺ១០០% នៃពិន្ទុសរុបដើម្បីទទួលបានរង្វាន់សម្រាប់ "សហគ្រិនដែលមានស្នាដៃផ្ញើម"។***

## ២.៦. រង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃផ្តើមខាងថែរក្សាឆ្នេរសមុទ្រ"

រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃផ្តើមខាងថែរក្សាឆ្នេរសមុទ្រ"**មាន ០៣សូចនាករ ដែលនឹងត្រូវផ្តល់ពិន្ទុតាមរយៈលក្ខណវិនិច្ឆ័យចំនួន ០៩ ដូចមានក្នុងតារាងខាងក្រោម៖

| **រង្វាន់** | **លក្ខណវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| **ធុរកិច្ចដែលមានស្នាដៃផ្តើមខាងថែរក្សាឆ្នេរសមុទ្រ (Beach Eco-Label Award)** | ការដាក់បញ្ចូលគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងសកម្មភាពអាជីវកម្មសំដៅឲ្យមានការចូលរួមរបស់ក្រុមហ៊ុនក្នុងការថែរក្សា គ្រប់គ្រង រៀបចំ និងអភិវឌ្ឍន៍ឆ្នេរសមុទ្រកម្ពុជាប្រកបដោយនិរន្តរភាពក្នុងបរិបទអភិរក្សធនធានធម្មជាតិ និងវប្បធម៌។ | | |
| | *-ការគ្រប់គ្រងឆ្នេរសមុទ្រ* | | |
| | 1-ការរៀបចំក្រុមការងារទទួលបន្ទុកគ្រប់គ្រងឆ្នេរ (Management Team/ Site Manager) | មាន-មិនមាន | ១៥% |
| | *-ការគិតគូរពីបរិស្ថាន* | | |
| | 2- ការគោរពបទដ្ឋានគតិយុត្ត និងបទបញ្ញត្តិស្តីពីបរិស្ថាន | មាន-មិនមាន | ១0% |
| | 3- ភាពស្អាតនៅទីសាធារណៈ និងទីកន្លែងទទួលសាធារណៈជន | មាន-មិនមាន | ១0% |
| | 4- ការគ្រប់គ្រងសំណល់ (រាវ និងរឹង) | មាន-មិនមាន | ១៥% |
| | 5- ការសន្សំសំចៃធនធាន ថាមពល និងការគិតគូរពីតំបន់បៃតង | មាន-មិនមាន | ១0% |
| | *-ព័ត៌មាន សុវត្ថិភាព និងការពេញចិត្តរបស់ភ្ញៀវទេសចរ* | | |
| | 6- ការបង្ហាញព័ត៌មានជាក់ស្តែង និងការអនុវត្តល្អៗនៃបទបញ្ញត្តិនៅតាមឆ្នេរសមុទ្រ | មាន-មិនមាន | ១0% |
| | 7- ការគិតគូរពីសន្តិសុខសុវត្ថិភាពនៅតាមឆ្នេរសមុទ្រ | មាន-មិនមាន | ១0% |
| | 8- ការគិតគូរពីសុវត្ថិភាពចំណីអាហារនៅតាមឆ្នេរសមុទ្រ | មាន-មិនមាន | ១0% |
| | 9- ការពេញចិត្តរបស់ភ្ញៀវទេសចរ | មាន-មិនមាន | ១0% |

### សេចក្តីអត្ថាធិប្បាយពីសូចនាករ និងលក្ខណវិនិច្ឆ័យ

រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃផ្តើមខាងថែរក្សាឆ្នេរសមុទ្រ"** មានគោលបំណងធ្វើយ៉ាងណាឲ្យមានការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយនិរន្តរភាព និងដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកឯកជន និងសាធារណៈ។ រង្វាន់ប្រភេទនេះមានសូចនាករចំនួន០៣ និងមានលក្ខណវិនិច្ឆ័យចំនួន០៩ ដែលមានលក្ខណៈដូចខាងក្រោម៖

**ក. សូចនាករទី១.** ***ការគ្រប់គ្រងឆ្នេរសមុទ្រ***

ឆ្នេរសមុទ្រដែលមានការអភិវឌ្ឍ និងភាពរីកចំរើនចាំបាច់ត្រូវមានការយកចិត្តទុកដាក់គ្រប់គ្រងឲ្យបានល្អ។ ដូច្នេះឆ្នេរបេក្ខភាពត្រូវមានក្រុមការងារមួយដែលទទួលបន្ទុកគ្រប់គ្រងឆ្នេរ ដើម្បីធ្វើការគ្រប់គ្រងឆ្នេរសមុទ្រឲ្យបានល្អ។

➢ **លក្ខណវិនិច្ឆ័យទី១. ការរៀបចំក្រុមការងារទទួលបន្ទុកគ្រប់គ្រងឆ្នេរ**

**(Management Team/SiteManager)**

ការរៀបចំក្រុមការងារទទួលបន្ទុកគ្រប់គ្រងឆ្នេរ (Management Team/ Site Manager) គឺពិតជា មានសារៈសំខាន់ចាំបាច់ជាមូលដ្ឋាន ដោយក្រុមការងារនេះនឹងទទួលបន្ទុកលើគ្រប់កិច្ចការជាទូទៅសំដៅធានាឲ្យមានការអភិវឌ្ឍឆ្នេរប្រកបដោយនិរន្តរភាព។ ដើម្បីធានាពីប្រសិទ្ធភាពការងារ ក្រុមការងារទទួលបន្ទុកគ្រប់គ្រងឆ្នេរចាំបាច់ត្រូវមានរចនាសម្ព័ន្ធតួនាទី និងភារកិច្ចច្បាស់លាស់។

**ខ. សូចនាករទី២. *ការគិតគូរពីបរិស្ថាន***

សូចនាករនេះមានគោលបំណងរួមគឺ ដើម្បីពញ្ញាក់អារម្មណ៍ដល់ប្រតិបត្តិករទេសចរណ៍ដែលទទួលផលប្រយោជន៍ពីឆ្នេរសមុទ្រទាំងឡាយឲ្យបានជ្រួតជ្រាបអំពីចំនុចគន្លឹះដែលគួរយកចិត្តទុកដាក់ ដើម្បីបញ្ចៀសផលប៉ះពាល់ទៅលើបរិស្ថានដែលអាចកើតចេញពីសកម្មភាពគ្រប់គ្រង និងអភិវឌ្ឍន៍នានា។ ដូច្នេះយើងបានកំនត់យកលក្ខណវិនិច្ឆ័យចំនួន០៥ដែលប្រតិបត្តិករតំបន់ឆ្នេរសមុទ្រគួរអនុវត្តតាមៈ

➢ **លក្ខណវិនិច្ឆ័យទី២. ការអនុវត្តតាមបទដ្ឋានគតិយុត្តិ និងបទបញ្ញត្តិ**

ឆ្នេរបេក្ខភាពត្រូវយកចិត្តទុកដាក់លើការអនុវត្តតាមច្បាប់ពាក់ព័ន្ធដែលមានស្រាប់។ ការមិនគោរពតាមបទបញ្ញត្តិនគរូបនីយកម្ម ត្រូវបានយកចិត្តទុកដាក់ជាពិសេស។

➢ **លក្ខណវិនិច្ឆ័យទី៣. ភាពស្អាតនៅតាមទីសាធារណៈ និងសម្បទាទទួលសាធារណៈជន**

ឆ្នេរបេក្ខភាពត្រូវធានាឲ្យបានថា តំបន់ឆ្នេរមិនមានសំរាមពាសវាលពាសកាល ត្រូវមានធុងសំរាមគ្រប់គ្រាន់ដើម្បីផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរក្នុងការបោះសំរាម។ កន្លែងធ្វើម្ហូប កន្លែងងូតទឹក បន្ទន់អនាម័យត្រូវធានាឲ្យមានភាពស្អាតជាប្រចាំ។ ឆ្នេរបេក្ខភាពត្រូវមានទីតាំងសម្រាប់ចំណតសមស្របដោយមិនប៉ះពាល់ដល់ចរាចរសាធារណៈ។ ដើម្បីទទួលបានពិន្ទុអតិបរមាឆ្នេរបេក្ខភាពត្រូវធ្វើសម្រង់ទីកន្លែងទាំងអស់នោះ ដោយមានការទទួលស្គាល់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច។

➢ **លក្ខណវិនិច្ឆ័យទី៤. ការគ្រប់គ្រងសំណល់ (រាវ និងរឹង)**

ឆ្នេរបេក្ខភាពត្រូវធានាឲ្យបានថា គ្រប់ប្រតិបត្តិករទេសចរទាំងអស់បំពាក់ប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវកខ្វក់ ដើម្បីធ្វើចំរុះធាតុកខ្វក់ពីសំណល់រាវទាំងអស់មុននឹងបញ្ចេញទៅប្រព័ន្ធលូបង្ហូរទឹកធម្មតា មិនតែប៉ុណ្ណោះទឹកដែលចេញពីប្រព័ន្ធប្រព្រឹត្តកម្មនោះគួរត្រូវបានយកទៅប្រើប្រាស់សម្រាប់ស្រោចសួនច្បារ សំអាតទីធ្លា ប្រើប្រាស់ក្នុងបង្គន់-ល-។

ចំពោះសំណល់រឹង ឆ្នេរបេក្ខភាពត្រូវធានាឲ្យបានថា គ្រប់ប្រតិបត្តិករទាំងអស់បានអនុវត្តនូវគោលការណ៍៣Rsការកាត់បន្ថយ (Reduce) ការប្រើប្រាស់ឡើងវិញ (Reuse) និងការកែច្នៃសំណល់ (Recycle) អនុវត្តការប្រមូលសំណល់ដោយមានការបែងចែកទៅតាមប្រភេទ ដូចជាសំណល់អាចកែច្នៃឡើងវិញបាន (ដូចជា សំបកដប កំប៉ុង ថង់ប្លាស្ទិក...) សំណល់សរីរាង្គ (បន្លែ ផ្លែឈើ សាច់ ... រលួយ ឬខូច) និងសំណល់ផ្សេងៗទៀតជាដើម និងមានការបំពាក់បំពាក់ធុងសំរាមចំនួន**៣ប្រភេទ** (ធុងសម្រាប់សំណល់សរីរាង្គ សំណល់កែច្នៃ និងសំណល់ផ្សេងៗ) នៅតាមទីធ្លាទីតាំងសំខាន់ៗ ពិសេសនៅតាមបណ្តោយឆ្នេរសមុទ្រ។

មិនតែប៉ុណ្ណោះ ឆ្នេរបេក្ខភាពត្រូវបង្កើតឲ្យមានជាគោលការកាត់បន្ថយសំរាមជាប្លាស្ទិក ដូចជាការប្រើប្រាស់ចានថ្មជំនួសឲ្យប្រអប់បាយប្លាស្ទិក លើកទឹកចិត្តឲ្យមានការប្រើប្រាស់សំបកវិចខ្ចប់ក្រៅពីប្លាស្ទិក។ ការយកសម្ភារះវិចខ្ចប់ជាកញ្ច្រែងធ្វើពីឫស្សី ឬធុងធ្វើពីដែក ដែលអាចប្រើប្រាស់បានច្រើនដង មុនទៅផ្សារទិញទំនិញ។

➢ **លក្ខណវិនិច្ឆ័យទី៥. ការសន្សំសំចៃធនធាន និងថាមពលនិងការគិតគូរពីតំបន់បៃតង**

ការកាត់បន្ថយឲ្យបានជាអតិបរមានូវការប្រើប្រាស់ទឹក និងថាមពលអគ្គិសនី តាមរយៈសកម្មភាពកាត់បន្ថយដោយផ្ទាល់ និងការប្រើប្រាស់សំភារៈបរិក្ខាណាដែលជួយសន្សំសំចៃទឹក និងថាមពល។ ឆ្នេរបេក្ខភាពត្រូវលើកទឹកចិត្តឲ្យប្រតិបត្តិករនៅតាមតំបន់ឆ្នេរចេះសន្សំសំចៃទឹក និងភ្លើងក្នុងប្រត្តិបត្តិការអាជីវកម្មរបស់ពួកគេតាមការដាក់សញ្ញា ឬពាក្យស្លោក (ឧទាហរណ៍៖ *"សូមមេត្តាកុំបើកភ្លើងចោល" "សូមមេត្តាបិទទឹកឲ្យជិតក្រោយពេលឈប់ប្រើប្រាស់"*) និងការប្រើប្រាស់ឧបករណ៍ដែលជួយសន្សំសំចៃ ដូចជាបង្គន់ និងរូបីណេដែលជួយសន្សំសំចៃទឹក អំពូលស៊ីភ្លើងតិច ឬឧបករណ៍ដែលប្រើប្រាស់ថាមពលកកើតឡើងវិញ ការប្រើប្រាស់ឧបករណ៍ដែលដើរដោយថាមពលពន្លឺព្រះអាទិត្យ ការរចនាអគារដែលមានទម្រង់គិតគូរដល់បរិស្ថាន (Eco Building) ជាដើម។ ការដាំដើមឈើនៅបរិវេណកន្លែងប្រកបរបរ ការបង្កើតជាសួនច្បារ ។ល។

**គ. សូចនាករទី៣. *ព័ត៌មាន សុវត្ថិភាព និងការពេញចិត្តរបស់ភ្ញៀវទេសចរ***

ការផ្តល់ព័ត៌មានតាមរយៈការបញ្ជ្រាបការយល់ដឹង ត្រូវធ្វើឡើងដើម្បីពញ្ញាក់ស្មារតីស្តីពីកំហុសឆ្គងផ្សេងៗដែលកើតចេញពីការអនុវត្តប្រចាំថ្ងៃ និងចង់ផ្សព្វផ្សាយ ឬណែនាំអំពី សីរិយាបថ និងការអនុវត្តល្អៗ។ ការធានានូវសន្តិសុខសុវត្ថិភាពដល់ភ្ញៀវទេសចរក៏ជាកិច្ចការដ៏ចាំបាច់មួយផងដែរ ដើម្បីធានាឲ្យបាននូវ សុវត្ថិភាពនៃអ្នកលេងកំសាន្ត និងការងូតទឹកកំសាន្តនៅលើឆ្នេរសមុទ្រ។ សូចនាករទី៣នេះត្រូវបានកំនត់ ដោយលក្ខណៈវិនិច្ឆ័យចំនួន ០៤ ដូចខាងក្រោម៖

➢ **លក្ខណវិនិច្ឆ័យទី៦. ការបង្ហាញព័ត៌មានជាក់ស្តែង និងការអនុវត្តល្អៗនៃបទបញ្ញត្តិនៅតាមឆ្នេរសមុទ្រ**

ឆ្នេរសមុទ្របេក្ខភាព ត្រូវបញ្ជ្រាបការយល់ដឹងទៅប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរអំពី ព័ត៌មានដូចខាងក្រោម៖

- ប្លង់ឆ្នេរសមុទ្រជាមួយនឹងសម្បទា សេវាកម្ម និងមានព័ត៌មានចាំបាច់នានាដូចជា (អាកាសធាតុ សីតុណ្ហភាពនៃទឹក ពេលវេលានៃការងូតទឹកកំសាន្តដែលមានការត្រួតពិនិត្យ...)
- ព័ត៌មានទាក់ទងនឹងបរិស្ថាន សេដ្ឋកិច្ច និងសង្គម (មជ្ឈដ្ឋានប្រព័ន្ធអេកូឡូស៊ី ប្រជាសាស្ត្រ វប្បធម៌ និងសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់)
- ការអនុវត្តល្អៗសម្រាប់អ្នកកំសាន្តនៅលើឆ្នេរ
- ចំនុចសំខាន់ៗនៃបទបញ្ញត្តិនៅតាមឆ្នេរសមុទ្រ៖ បំរាម ការកំណត់ច្រកចូល បទបញ្ជានៃការ បែងចែកតំបន់ទៅតាមសកម្មភាពនានា

សកម្មភាពបញ្ជ្រាបការយល់ដឹងអាចធ្វើឡើងក្រោមទម្រង់ជាកិច្ចប្រជុំជាសាធារណៈ យុទ្ធនាការចែកខិតប័ណ្ណដោយដៃផ្ទាល់ កូនសៀវភៅណែនាំ ឬក៏ផូស្ទ័រ ប័ណ្ណផ្ទត់ ប័ណ្ណផ្សព្វផ្សាយជាដើម ជាខេមរៈភាសា និងភាសាអង់គ្លេស)។

➢ **លក្ខណវិនិច្ឆ័យទី៧. ការគិតគូរពីសន្តិសុខសុវត្ថិភាពនៅតាមឆ្នេរសមុទ្រ**

ការគ្រប់គ្រងពីសន្តិសុខសុវត្ថិភាពនៅតាមឆ្នេរសមុទ្រ សំដៅដល់ការបង្កើតឲ្យមានប្រព័ន្ធដែល អាចធានាឲ្យមានសន្តិសុខសុវត្ថិភាព ដូចជាការបង្កើតឆ្មាំឆ្នេរសមុទ្រគ្រប់គ្រាន់តាមតម្រូវការចាំបាច់ ការរៀបចំឲ្យមានកន្លែងសង្គ្រោះបន្ទាន់ដែលមានក្រុមការងារ និងឧបករណ៍សង្គ្រោះគ្រប់គ្រាន់ជូនដល់ភ្ញៀវទេសចរ និងការរៀបចំនូវសញ្ញាចង្អុលបង្ហាញដែលអនុញ្ញាតឲ្យភ្ញៀវដឹងពីសញ្ញាណនៃគ្រោះថ្នាក់ ជាដើម។

➢ **លក្ខណៈវិនិច្ឆ័យទី៨. ការគិតគូរពីសុវត្ថិភាពចំណីអាហារនៅតាមឆ្នេរសមុទ្រ**

បញ្ហាសុវត្ថិភាពចំណីអាហារនៅតាមអាហារដ្ឋានគ្រប់ប្រភេទ ជាបញ្ហាចាំបាច់មួយដែលត្រូវមានការយកចិត្តទុកដាក់ខ្ពស់ ពិសេសបញ្ហាអនាម័យ និងគុណភាពនៃចំណីអាហារដែលបម្រើដល់ភ្ញៀវទេសចរ។ ឆ្នេរបេក្ខភាព ត្រូវមានយន្តការ និងវិធានការត្រួតពិនិត្យពីសុវត្ថិភាពចំណីអាហារឲ្យបានជាប្រចាំ។

➢ **លក្ខណៈវិនិច្ឆ័យទី៩. ការពេញចិត្តរបស់ភ្ញៀវទេសចរ**

ឆ្នេរបេក្ខភាពត្រូវធ្វើការសិក្សាពីការពេញចិត្តរបស់ភ្ញៀវទេសចរ តាមរយៈការធ្វើអង្កេតស្ទង់មតិក្រោមទម្រង់ជាកម្រងសំណួរ ដើម្បីស្វែងយល់ពីភាពខ្លាំង និងភាពខ្សោយនៃការអភិវឌ្ឍរបស់ឆ្នេរសមុទ្រ។ លទ្ធផលនៃការអង្កេតនេះមានសារៈសំខាន់ដែលអាចឲ្យអ្នកគ្រប់គ្រងឆ្នេរធ្វើការកែតម្រូវពីចំនុចខ្វះខាតរបស់ខ្លួន។

***ចំពោះរង្វាន់ប្រភេទនេះ គឺទាមទារឲ្យសហគ្រាសបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងអស់តែម្តង ពោលគឺ ១០០% នៃពិន្ទុសរុបដើម្បីទទួលបានរង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្លាកដៃផ្តើមខាងថែរក្សាឆ្នេរសមុទ្រ" ។***

### ២.៧. រង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ"

Khmer Product Usage Award

ដើម្បីធានាឲ្យមានការបែងចែកផ្លែផ្កានៃកំណើនពីវិស័យទេសចរណ៍ប្រកបដោយសមធម៌ ពិសេសការលើកស្ទួយ *"វិស័យទេសចរណ៍ ជាការនាំចេញនៅនឹងកន្លែង"* ក្រសួងទេសចរណ៍បានដាក់ចេញនូវ យុទ្ធនាការ **"រួមគ្នាប្រើប្រាស់ផលិតផលខ្មែរក្នុងឧស្សាហកម្មទេសចរណ៍"** ដែលនឹងជួយដល់ផលិតករក្នុងស្រុក ដែលជាប្រជាកសិករ ម្ចាស់កសិដ្ឋាន ម្ចាស់សិប្បកម្ម ម្ចាស់សហគ្រាសធនតូច និងមធ្យម (SMEs) ផលិតវត្ថុអនុស្សាវរីយ៍ និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការទទួលបានឱកាសបន្ថែមក្នុងការផ្សព្វផ្សាយ និងស្វែងរកទីផ្សារសម្រាប់ផលិតផលខ្មែរនៅក្នុងឧស្សាហកម្មទេសចរណ៍។

ក្នុងន័យនេះ រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ"** ត្រូវបានបង្កើតឡើងក្នុងគោលបំណងជំរុញការប្រើប្រាស់ផលិតផលខ្មែរ ដែលផលិតដោយប្រជាកសិករ សិប្បករ ឬផលិតករក្នុងស្រុក នៅក្នុងឧស្សាហកម្មទេសចរណ៍ សំដៅរកទីផ្សារ បង្កើនប្រាក់ចំណូលបន្ថែម និងលើកកម្ពស់កំរិតជីវភាពរបស់ប្រជាពលរដ្ឋ។

រង្វាន់សម្រាប់ **"ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ"** នឹងត្រូវធ្វើការវាយតម្លៃផ្តល់ពិន្ទុដោយផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ០៣ ដូចខាងក្រោម៖

| ល.រ | លក្ខណៈវិនិច្ឆ័យ | ចំនុចសារសំខាន់ | ពិន្ទុ |
|---|---|---|---|
| 1. | **ចក្ខុវិស័យច្បាស់លាស់ក្នុងការប្រើប្រាស់ផលិតផលខ្មែរ** | - មានគោលការណ៍ច្បាស់លាស់ក្នុងការប្រើប្រាស់ផលិតផលខ្មែរ<br>- គោលការណ៍ទាំងនោះចាំបាច់ត្រូវបញ្ចូលក្នុងគម្រោងផែនការអាជីវកម្ម | ៣០% |
| 2. | **សកម្មភាពអនុវត្តជាក់ស្តែង** | - ត្រូវមានការអនុវត្តជាក់ស្តែងទៅតាមគោលការណ៍ ដោយមានបញ្ជាក់អំពីប្រភេទផលិតផលដែលប្រើប្រាស់<br>- កំរិតនៃការប្រើប្រាស់ផលិតផលខ្មែរ យ៉ាងហោចណាស់ ៣០% នៃផលិតផលដែលប្រើប្រាស់សរុបនៅក្នុងទីតាំងអាជីវកម្ម | ៣០% |
| 3. | **វត្តមានកិច្ចសន្យាជាមួយផលិតករក្នុងស្រុក** | - ត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយប្រជាកសិករ សិប្បករ ឬផលិតករក្នុងស្រុក ក្រោមទំរង់ជាកិច្ចសន្យាផ្គត់ផ្គង់*រយៈពេលមធ្យម ឬវែង* ដើម្បីធានាដល់ការផ្គត់ផ្គង់ទាន់ពេលវេលា និងប្រកបដោយគុណភាព | ៤០% |

#### សេចក្តីអត្ថាធិប្បាយអំពីលក្ខណៈវិនិច្ឆ័យ

**លក្ខណៈវិនិច្ឆ័យទី១៖ ចក្ខុវិស័យច្បាស់លាស់ក្នុងការប្រើប្រាស់ផលិតផលខ្មែរ**

ក្រុមហ៊ុន/សហគ្រាសត្រូវមានគោលការណ៍ច្បាស់លាស់ក្នុងការជំរុញ និងលើកស្ទួយការប្រើប្រាស់ផលិតផលខ្មែរ ដែលផលិតដោយប្រជាកសិករ សិប្បករ ឬផលិតករក្នុងស្រុក ពោលគឺត្រូវមានគោលការណ៍ក្នុង

ការប្រើប្រាស់បន្លែ ផ្លែឈើ សាច់ គ្រឿងសង្ហារឹម វត្ថុអនុស្សាវរីយ៍ និងវត្ថុធាតុដើមក្នុងស្រុក ជាដើមឲ្យបានជាអតិបរមា លើកលែងតែផលិតផលមួយចំនួនដែលមិនមានផលិតនៅក្នុងស្រុក។ គោលការណ៍ទាំងនេះទាមទារចាំបាច់ឲ្យមានចែងក្នុងផែនការអាជីវកម្មរបស់ខ្លួន ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន/សហគ្រាសក្នុងការចូលរួមលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាកសិករ សិប្បករ និងផលិតករក្នុងស្រុក។

**លក្ខណៈវិនិច្ឆ័យទី២៖ សកម្មភាពអនុវត្តជាក់ស្តែង**

ទន្ទឹមនឹងការរៀបចំបង្កើតឲ្យមានគោលការណ៍ច្បាស់លាស់ហើយ ក្រុមហ៊ុន/សហគ្រាសបង្ហាញពីការអនុវត្តជាក់ស្តែង ថាតើនៅក្នុងសហគ្រាសមានប្រើប្រាស់ផលិតផលខ្មែរប្រភេទណាខ្លះ និងក្នុងកំរិតណា ដោយត្រូវមានយ៉ាងហោចណាស់ **៣០%**នៃផលិតផលប្រើប្រាស់សរុបនៅក្នុងទីតាំងអាជីវកម្ម ជាផលិតផលខ្មែរ។

**លក្ខណៈវិនិច្ឆ័យទី៣៖ វត្តមានកិច្ចសន្យា**

ក្រុមហ៊ុន/សហគ្រាសត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយប្រជាកសិករ សិប្បករ ឬផលិតករក្នុងស្រុក តាមរយៈការ**ចុះកិច្ចសន្យា**ផ្គត់ផ្គង់*រយៈពេលមធ្យម និងវែង* ដើម្បីធានាការផ្គត់ផ្គង់ឲ្យបានទាន់ពេលវេលា ប្រកបដោយគុណភាព និងធានាស្ថិរភាពនៃតម្លៃផងដែរ។ កិច្ចសន្យានេះក៏នឹងផ្តល់ទំនុកចិត្តដល់ប្រជាកសិករ សិប្បករ ឬផលិតករក្នុងស្រុកលើការធានាការទទួលទិញពីផ្នែកតម្រូវការផងដែរ ដែលនឹងជម្រុញឲ្យពួកគាត់បង្កើនផលិតភាព និងគុណភាពផលិតផលខ្មែរ។

***ចំពោះរង្វាន់ប្រភេទនេះ គឺទាមទារឲ្យក្រុមហ៊ុន/សហគ្រាសបំពេញតាមលក្ខណវិនិច្ឆ័យទាំង០៣នេះ ឲ្យបាន ១០០% ដើម្បីទទួលបានរង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ" ។***

## III. **អេកូឡាប៊ិល និងវិញ្ញាបនបត្រទទួលស្គាល់**

អេកូឡាប៊ិលត្រូវបានរៀបចំឡើងមាន **០៧ប្រភេទ**ដូចខាងក្រោម៖

- ទី១.រង្វាន់សម្រាប់ **“ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន”**

  (Environment Award)

- ទី២.រង្វាន់សម្រាប់**“ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍៣Rs”**(3Rs Award)

- ទី៣.រង្វាន់សម្រាប់**“ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌”**(Social Welfare and Cultural Heritage Award)

- ទី៤.រង្វាន់សម្រាប់**“ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកន្លែងធ្វើការដែលមានភាពល្អប្រសើរ”**

  (Best Workplace Award)

- ទី៥.រង្វាន់សម្រាប់ **“សហគ្រិនដែលមានស្នាដៃឆ្នើម”** (Entrepreneur Award)

- ទី៦.រង្វាន់សម្រាប់ **“ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាឆ្នេរសមុទ្រ”**

  (Beach Eco-Label Award)

- ទី៧. រង្វាន់សម្រាប់ **“ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ”**

  (Khmer Product Usage Award)

❖ វិញ្ញាបនបត្រទទួលស្គាល់សហគ្រាសគំរូ និងបុគ្គលគំរូ មាន ០៦ ប្រភេទ៖



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...................

# វិញ្ញាបនបត្រទទួលស្គាល់

**THIS IS TO CERTIFY THAT**

.......................................................................

បានបំពេញតាមលក្ខណៈវិនិច្ឆ័យក្នុងការទទួលបាន

រង្វាន់សម្រាប់៖ "ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន"

HAS COMPLIED WITH REQUIREMENT PRESCRIBED BY

ECO-BUSINESS

ENVIRONMENT AWARD

**សុពលភាព៖ ២០១៥ - ២០១៧**

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ២០.....

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
ប្រធាន

ថោង ខុន
រដ្ឋមន្ត្រីក្រសួងទេសចរណ៍

**វិញ្ញាបនបត្រទទួលស្គាល់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន"**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..................

# វិញ្ញាបនបត្រទទួលស្គាល់

## THIS IS TO CERTIFY THAT

...........................................................

**បានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងការទទួលបាន**

**រង្វាន់សម្រាប់:"ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ 3RS"**

HAS COMPLIED WITH REQUIREMENT PRESCRIBED BY

**សុពលភាព៖ ២០១៥ - ២០១៧**

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ២០.....

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
**ប្រធាន**

**ថោង ខុន**
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វិញ្ញាបនបត្រទទួលស្គាល់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ ៣Rs"**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..................

# វិញ្ញាបនបត្រទទួលស្គាល់

## THIS IS TO CERTIFY THAT

..............................................................

**បានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងការទទួលបាន**

**រង្វាន់សម្រាប់:"ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌"**

HAS COMPLIED WITH REQUIREMENT PRESCRIBED BY

ECO-BUSINESS
SOCIAL WELFARE & CULTURAL HERITAGE AWARD

**សុពលភាព៖ ២០១៥ - ២០១៧**

រាជធានីភ្នំពេញ ថ្ងៃទី........ខែ...........ឆ្នាំ២០.....

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
**ប្រធាន**

**ថោង ខុន**
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វិញ្ញាបនបត្រទទួលស្គាល់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកសុខុមាលភាពសង្គម និងបេតិកភណ្ឌ វប្បធម៌"**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:.................

# វិញ្ញាបនបត្រទទួលស្គាល់

## THIS IS TO CERTIFY THAT

.....................................................................

**បានបំពេញតាមលក្ខណៈតម្រូវក្នុងការទទួលបាន**

**រង្វាន់សម្រាប់:"ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ"**

**HAS COMPLIED WITH REQUIREMENT PRESCRIBED BY**

ECO-BUSINESS

BEST WORKPLACE AWARD

**សុពលភាព៖ ២០១៥ - ២០១៧**

រាជធានីភ្នំពេញ ថ្ងៃទី........ខែ...........ឆ្នាំ២០.....

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វិញ្ញាបនបត្រទទួលស្គាល់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមផ្នែកកន្លែងធ្វើការដែលមានភាពល្អប្រសើរ"**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..................

# វិញ្ញាបនបត្រទទួលស្គាល់

## THIS IS TO CERTIFY THAT

..............................................................

**បានបំពេញតាមលក្ខណៈតម្រូវក្នុងការទទួលបាន**

**រង្វាន់សម្រាប់: "សហគ្រិនដែលមានស្នាដៃឆ្នើម"**

HAS COMPLIED WITH REQUIREMENT PRESCRIBED BY

**សុពលភាព: ២០១៥ - ២០១៧**

រាជធានីភ្នំពេញ ថ្ងៃទី........ខែ...........ឆ្នាំ២០.....

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
ប្រធាន

ថោង ខុន
រដ្ឋមន្ត្រីក្រសួងទេសចរណ៍

**វិញ្ញាបនបត្រទទួលស្គាល់ "សហគ្រិនដែលមានស្នាដៃឆ្នើម"**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..................

# វិញ្ញាបនបត្រទទួលស្គាល់

## THIS IS TO CERTIFY THAT

..............................................................

បានបំពេញតាមលក្ខណ្ឌតម្រូវក្នុងការទទួលបាន

រង្វាន់សម្រាប់៖ **"ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាឆ្នេរសមុទ្រ"**

HAS COMPLIED WITH REQUIREMENT PRESCRIBED BY

ECO-BUSINESS
BEACH ECO-LABEL AWARD

**សុពលភាព៖ ២០១៥ - ២០១៧**

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ២០.....

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
**ប្រធាន**

**ថោង ខុន**
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វិញ្ញាបនបត្រទទួលស្គាល់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាឆ្នេរសមុទ្រ"**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ..................

# វិញ្ញាបនបត្រទទួលស្គាល់

## THIS IS TO CERTIFY THAT

______________________________________

**បានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងការទទួលបាន**

**រង្វាន់សម្រាប់៖ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ"**

HAS COMPLIED WITH REQUIREMENT PRESCRIBED BY

**សុពលភាព៖ ២០១៥-២០១៧**

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០......

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
**ប្រធាន**

**ថោង ខុន**
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វិញ្ញាបនបត្រទទួលស្គាល់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ"**

សហគ្រាស ឬប្រតិបត្តិករទេសចរណ៍ ឬសហគមន៍ ឬបុគ្គលទាំងអស់ដែលបំពេញធុរកិច្ចក្នុងវិស័យទេសចរណ៍ និងវិស័យគាំទ្រអាចដាក់**ពាក្យសុំចូលរួមដោយស្ម័គ្រចិត្ត**នៅក្នុងប្រភេទរង្វាន់ណាមួយ ឬច្រើនប្រភេទរង្វាន់ក៏បាន។ វិញ្ញាបនបត្រទទួលស្គាល់ និងឡាបិលដែលមាន**សុពលភាពសម្រាប់រយៈពេល ២ ឆ្នាំ**នឹងត្រូវផ្តល់ជូនដល់សហគ្រាសគំរូ និងបុគ្គលគំរូណាដែលមានលទ្ធភាព និងសមត្ថភាពក្នុងការបំពេញតាមលក្ខណវិនិច្ឆ័យ។ ក្នុងកំឡុងពេលនៃសុពលភាពឡាបិលនេះ នឹងមានការចុះត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃការអនុវត្តរបស់សហគ្រាស និងបុគ្គលជ័យលាភីស្របតាមស្តង់ដារ**រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍**នេះ។ ក្នុងករណីដែលសហគ្រាស ឬបុគ្គលជ័យលាភីណាអនុវត្តមិនបានត្រឹមត្រូវតាមស្មារតីនៃស្តង់ដានេះ នឹងអាចឈានទៅដល់ការដកហូតឡាបិល។

## IV. យន្តការ និងនីតិវិធីសម្រាប់ដាក់ឱ្យដំណើរការឡាបិល

### ៤.១. យន្តការនៃការដាក់ឱ្យដំណើរការ

តាមការសិក្សាក្នុងការចងក្រងរៀបចំស្តង់ដានេះ យន្តការស្ថាប័នសម្រាប់ដាក់ឱ្យដំណើរការតម្រូវឱ្យមានភាគីទី១ (**"ស្ថាប័នរដ្ឋមួយ"**) ដើម្បីធ្វើការវាយតម្លៃអំពីភាពត្រឹមត្រូវតាមលក្ខណៈ និងស្ថានភាពជាក់ស្តែងរបស់បេក្ខភាពនីមួយៗ។ ក្នុងន័យនេះ **ក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**នឹងដើរតួជាស្ថាប័នរដ្ឋ ប៉ុន្តែដើម្បីឱ្យការអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់តម្រូវឱ្យមានភាគីទី២ (ជា**"ស្ថាប័នឯករាជ្យ"**) សម្រាប់ជួយប្រឹក្សាយោបល់ ផ្តល់ការណែនាំ និងពង្រឹងសមត្ថភាពសហគ្រាសដើម្បីឈានទៅទទួលបានរង្វាន់។

### ៤.២. នីតិវិធីនៃដំណើរការ

សហគ្រាស ឬបុគ្គលទាំងអស់ដែលបំពេញធុរកិច្ចក្នុងវិស័យទេសចរណ៍ និងវិស័យគាំទ្រអាចចូលរួមកម្មវិធីប្រឡងប្រណាំងយក**"រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"** បានតាមរយៈការបំពេញតាមដំណាក់កាលដូចខាងក្រោម៖

- **ដំណាក់កាលទី១៖** បេក្ខជនត្រូវដាក់ពាក្យសុំ និងផ្ញើមកកាន់ក្រសួងទេសចរណ៍រាល់ថ្ងៃក្នុងម៉ោងធ្វើការ ដោយមានភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធ។ បេក្ខជនអាចស្វែងរកស្ថាប័នឯករាជ្យមួយដែលមានជំនាញក្នុងការប្រឹក្សាយោបល់ និងបច្ចេកទេសលើការបំពេញពាក្យសុំ ការរៀបចំឯកសារពាក់ព័ន្ធ និងពង្រឹងលក្ខណៈសម្បត្តិក្នុងការដណ្តើមយកជ័យលាភី។ ទម្រង់នៃពាក្យសុំ និងបែបបទនៃការដាក់ពាក្យ និងឯកសារពាក់ព័ន្ធត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍។
- **ដំណាក់កាលទី២៖** ក្រសួងទេសចរណ៍ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនៃការចាប់ផ្តើមការវាយតម្លៃបឋម។ រាល់ពាក្យសុំទាំងឡាយណាដែលបានដាក់ក្រោយកាលបរិច្ឆេទនេះ ត្រូវបានរក្សាទុកដើម្បីធ្វើការវាយតម្លៃសម្រាប់ការប្រឡងប្រណាំងនៅឆ្នាំបន្ទាប់។
- **ដំណាក់កាលទី៣៖** ក្រសួងទេសចរណ៍មានរយៈពេល **ហុកសិបថ្ងៃ (៦០)** ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃបឋមលើពាក្យសុំ និងឯកសារពាក់ព័ន្ធនៃបេក្ខជនទាំងឡាយ ដែលបានដាក់ពាក្យសុំមុនកាលបរិច្ឆេទនៃការចាប់ផ្តើមការវាយតម្លៃបឋម។
- **ដំណាក់កាលទី៤៖** ក្រសួងទេសចរណ៍ត្រូវជូនដំណឹងពីលទ្ធផលនៃការវាយតម្លៃបឋម និងត្រូវចាត់ក្រុមការងារដើម្បីចុះពិនិត្យ និងវាយតម្លៃនៅតាមទីតាំងរបស់បេក្ខភាពដែលបាន

ជាប់ក្នុងការវាយតម្លៃបឋម ក្នុងកំឡុងពេល **ហុកសិបថ្ងៃ (៦០)** គិតចាប់ពីថ្ងៃជូនដំណឹងនេះ។

- **ដំណាក់កាលទី៥៖** ក្រសួងទេសចរណ៍ត្រូវចេញជារបាយការណ៍វាយតម្លៃចុងក្រោយ និងការប្រកាសជ័យលាភីរ**ង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍** ក្នុងរយៈពេល **សាមសិបថ្ងៃ(៣០)** គិតចាប់ពីថ្ងៃបញ្ចប់ការចុះវាយតម្លៃតាមទីតាំង។
- **ដំណាក់កាលទី៦៖** ក្រសួងទេសចរណ៍នឹងរៀបចំពិធីប្រគល់រង្វាន់ដល់ជ័យលាភី **"រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"** ជារៀងរាល់ឆ្នាំ។